ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# ភាសាខ្មែរ

## អាន-សរសេរ



១

ក្រសួងអប់រំ យុវជន និងកីឡា

# ភាសាខ្មែរ

# អាន-សរសេរ

## ថ្នាក់ទី ១

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ២២៥៥ អយក.ប្រក. ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០១១ ដើម្បីប្រើប្រាស់នៅតាមសាលារៀន។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ**

បោះពុម្ពឆ្នាំ២០១៦

ISBN 9-789-995-001-674

## គណៈកម្មការគ្រប់គ្រងកម្មវិធី

ឯកឧត្តម អ៊ឹម សិទ្ធី

ឯកឧត្តម ណាត ប៊ុនរឿន

ឯកឧត្តម កើ ណៃលាង

លោកជំទាវ ទន់ សាអ៊ឹម

ឯកឧត្តម អ៊ូ អេង

លោក ចាន់ សុភា

## គណៈកម្មការនិពន្ធ

លោក ផាត់ វ៉ាន់ថន

លោក យិន ស៊ីដា

លោកស្រី ឈឹន ស៊ីវឡេង

លោក មួង ចាន់ទូច

លោកស្រី លី សាខុន

លោក សុខ បូរេត

លោកស្រី ម៉ៅ តាន់ណារី

លោក យិត សុភ័ក្ត្រ

លោក យ៉ោក សុវណ្ណ

លោក អ៊ុយ សាន

លោក ជិន សុកហេង

លោក កែវ សារ៉ាត់

## គណៈកម្មការរៀបរៀង វិចិត្រករ និងរចនាទំព័រ

លោក យិន ស៊ីដា

លោក ញេប ប៊ុនស្រេង

លោក រ័ត្ន ប៊ុណ្ណា

លោក សូ ស៊ីផុន

លោក ហុង ពិដោរ

លោក ឡុង សុវណ្ណ(វិចិត្រករ)

## គណៈកម្មការពិនិត្យ

លោក ចាន់ សុភា

លោក អេង គឹមលី

លោក លាង សេងហាក់

លោក បេង ស៊ីម៉េត

លោក ជុំ សុផល

# អារម្ភកថា

សៀវភៅភាសាខ្មែរ "អាន-សរសេរ" ថ្នាក់ទី ១ នេះត្រូវបានរៀបចំឡើងដោយគណៈកម្មការនិពន្ធក្រសួងអប់រំ យុវជន និងកីឡា ដែលមានការចូលរួមសហការពីនាយកដ្ឋានបឋមសិក្សា នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងលោកនាយក លោកស្រីនាយិកា លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី ១ មួយចំនួនដែលស្ថិតនៅក្រោមគម្រោងកម្មវិធីសកម្មភាពពង្រីកការគាំទ្រវិស័យអប់រំ និងដៃគូអភិវឌ្ឍមួយចំនួន ។

សៀវភៅនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងសម្រួល ដល់ការរៀនអក្សរដំបូងរបស់កុមារ ។ ខ្លឹមសារសំខាន់ៗនៃសៀវភៅនេះ មានការរៀបចំតាមលំដាប់ពីតិចទៅច្រើនពីងាយទៅលំបាក ដើម្បីជួយដល់ការរៀនអក្សរដំបូងរបស់កុមារ ឱ្យចេះអាន(ចេះប្រកប)និងចេះសរសេរបានត្រឹមត្រូវ ដោយចាប់ផ្តើមដំបូងពី ការរៀនស្រះ ព្យញ្ជនៈ ព្យញ្ជនៈផ្សំស្រះប្រកប ស្រះពេញតួ ផ្ញើជើង និងព្យាង្គតម្រួត ដោយចេះប្រកប ចេះអានពាក្យ ឃ្លា ល្បះអត្ថបទខ្លីៗ និងចេះសរសេរបានត្រឹមត្រូវច្បាស់លាស់ តាមរយៈការហាត់អាន សរសេរនិងការធ្វើកិច្ចការផ្ទះ ។ ពិសេសគឺ ផ្តោតទៅលើការពង្រឹងសមត្ថភាពអាន និងសរសេរ ដែលជាមូលដ្ឋានគ្រឹះសំខាន់ ក្នុងការសិក្សាអក្សរដំបូងរបស់សិស្សថ្នាក់ទី ១ ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅនេះនឹងបានជាប្រយោជន៍យ៉ាងច្រើនចំពោះសហគមន៍មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស ក៏ដូចជាសាលារៀន គ្រូបង្រៀនក្នុងការជួយបង្រៀនកុមារឱ្យចេះអាន ចេះសរសេរគ្រប់គ្នា ហើយសិស្សមានសមត្ថភាពអាន និងសរសេររឹងមាំ អាចបន្តការសិក្សាទៅថ្នាក់បន្ទាប់ទៀតបានប្រកបដោយគុណភាពពិតប្រាកដ ។

**គណៈកម្មការនិពន្ធ**

# មាតិកា

## គណៈកម្មការគ្រប់គ្រងកម្មវិធី


**អារម្ភកថា**........................................i

**មាតិកា**........................................ii

១. សេចក្ដីណែនាំ........................................iii

២. លំនាំបង្រៀន........................................ix

៣. មេរៀន

- រៀនគូសបន្ទាត់ និងខ្សែកោង........................................១
- ចម្រៀងស្រះ........................................២
- ស្រះនិស្ស័យ........................................៣
- ចម្រៀងអក្ខរក្រម........................................៤
- ព្យញ្ជនៈ ៣៣តួ........................................៥
- ព្យញ្ជនៈពួក អ........................................៦
- ព្យញ្ជនៈពួក អ៊........................................២១
- រៀនសាឡើងវិញព្យញ្ជនៈពួក អ និងពួកអ៊........................................៣៨
- បទចម្រៀង សារិកាកែវអើយ........................................៣៩
- សញ្ញាមូសិកទន្ត ឬសញ្ញាធ្មេញកណ្ដុរ ( ៉ )........................................៤០
- សញ្ញាត្រីស័ព្ទ ឬសញ្ញាសក់ ក ( ៊ )........................................៤៨
- ប្រកប........................................៥៤
- ស្រះពេញតួ........................................៨១
- ព្យញ្ជនៈ និងជើងព្យញ្ជនៈ........................................៨៤
  ព្យញ្ជនៈផ្ញើជើង........................................៨៥
- ព្យាង្គតម្រួត........................................១២២
- អត្ថបទ " អ្នកគ្រូខ្ញុំ "........................................១៣៣
- អត្ថបទ " សាលារៀនខ្ញុំ "........................................១៣៤

៤. បទានុក្រម........................................១៣៥

# សេចក្ដីណែនាំ

ផ្អែកតាមលទ្ធផលសិក្សារបស់សិស្សប៉ុន្មានឆ្នាំកន្លងមកនេះ យើងឃើញថា សិស្សបឋមសិក្សាមានមូលដ្ឋាននៃការអាន និងសរសេរ នៅមានកម្រិតទាបគួរឱ្យបារម្ភ ។ ក្រសួងអប់រំ យុវជន និងកីឡា បានរិះរកយុទ្ធវិធី ដើម្បីពង្រឹងគុណភាពនៃការអាន និងសរសេរ ឱ្យបានកាន់តែប្រសើរ ដោយធ្វើការសម្របសម្រួលវិធីសាស្ត្រ និងកែលម្អឯកសារសម្រាប់បង្រៀនភាសាខ្មែរថ្នាក់ទី ១ ឡើងវិញ ដើម្បីឱ្យសិស្សថ្នាក់ទី១ អាចរៀនភាសាខ្មែរឆាប់ចេះ ក្នុងទិសដៅឆ្លើយតបទៅនឹងគោលនយោបាយ សម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាដែលបានចែងថា សិស្សថ្នាក់ទី ១ ដល់ទី ៣ ត្រូវមានបំណិនមូលដ្ឋានរឹងមាំផ្នែកភាសាខ្មែរ និងគណិតវិទ្យាពោលគឺចេះអាន សរសេរ និងគិតលេខបានច្បាស់លាស់ ។

សៀវភៅសម្រាប់បង្រៀនអក្សរថ្នាក់ទី ១ ថ្មីនេះ រៀបរៀងឡើងដើម្បីសម្រួលដល់ការរៀន និងការបង្រៀនភាសាខ្មែរ ដោយដកស្រង់ខ្លឹមសារមួយចំនួន និងយកតាមលំនាំសៀវភៅថ្នាក់ទី ១ ពីសម័យមុនៗ មកធ្វើបច្ចុប្បន្នភាពឱ្យស្របតាមបរិបទថ្មី ។ សៀវភៅនេះចាប់ផ្ដើមពី **ការរៀនគូសបន្ទាត់ ស្រៈនិស្ស័យ ព្យញ្ជនៈ ព្យញ្ជនៈផ្សំនឹងស្រៈ ប្រកប ព្យញ្ជនៈផ្ញើជើង ព្យាង្គតម្រួត** ដើម្បីឱ្យសិស្សមានបំណិនរឹងមាំក្នុងការអាន ផ្សំព្យញ្ជនៈជាមួយស្រៈ និងឈានឆ្ពោះទៅប្រកប អានពាក្យ អានល្បះ និងអានអត្ថបទ ។ ក្រសួងអប់រំ យុវជន និងកីឡាប្រើប្រាស់សៀវភៅនេះ ដើម្បីអនុវត្តទូទាំងប្រទេស បន្ទាប់ពីបានធ្វើការសាកល្បងពេញមួយឆ្នាំសិក្សា ប្រកបដោយជោគជ័យ នៅតាមសាលាគោលដៅនៃរាជធានី ខេត្តមួយចំនួន ។

ដើម្បីជាជំនួយដល់គ្រូក្នុងការប្រើប្រាស់សៀវភៅនេះបានត្រឹមត្រូវ គណៈកម្មការបានរៀបចំសេចក្ដីណែនាំអមក្នុងសៀវភៅនេះ ដោយផ្ដោតលើ ៖

១. ការប្រើប្រាស់ម៉ោងសិក្សា

២. វិធីសាស្ត្រ

៣. ការប្រើប្រាស់សម្ភារៈ

៤. ការវាយតម្លៃ

៥. ការដាក់កិច្ចការផ្ទះ

៦. លំនាំបង្រៀន ។

# ១ . ការប្រើប្រាស់ម៉ោងសិក្សា

កម្មវិធីសិក្សាថ្មី តម្រូវឱ្យសិស្សសិក្សាភាសាខ្មែរចំនួន ១៣ម៉ោងក្នុងមួយសប្ដាហ៍ ហើយក្នុង១ម៉ោង សិក្សាមានរយៈពេល ៤០នាទី ។ ក្នុងមួយឆ្នាំសិក្សាសិស្សត្រូវរៀន ៣៨សប្ដាហ៍ ។ ដូច្នេះ ម៉ោងសម្រាប់ រៀនភាសាខ្មែរស្មើនឹង ៤៩៤ម៉ោងសិក្សា ។

ខាងក្រោមនេះ ជាកាលវិភាគសម្រាប់មុខវិជ្ជាភាសាខ្មែរក្នុង ១សប្ដាហ៍ ៖

| ថ្ងៃ | ចំនួនម៉ោងសិក្សា |
|---|---|
| ចន្ទ | ០៣ម៉ោង |
| អង្គារ | ០២ម៉ោង |
| ពុធ | ០៣ម៉ោង |
| សុក្រ | ០២ម៉ោង |
| សៅរ៍ | ០៣ម៉ោង |
| សរុប | ១៣ម៉ោង |

ចំនួនម៉ោងបង្រៀន នៅតាមទំព័រមេរៀននីមួយៗខុសៗគ្នា ។ ខ្លឹមសារមេរៀនខ្លះ ក្នុងមួយទំព័រត្រូវ បង្រៀន២ម៉ោង ខ្លះ៣ម៉ោង ខ្លះ៤ម៉ោង ខ្លះ៥ម៉ោង ខ្លះទៀតលើសពីដប់ម៉ោងក៏មាន ។ អាស្រ័យ ហេតុនេះ មុនពេលរៀបចំការបង្រៀនអ្នកគ្រូ លោកគ្រូ គប្បីមើលតារាងបែងចែកម៉ោងសិក្សាខាងក្រោម ជាមុនសិន ។

# តារាងបែងចែកម៉ោងសិក្សាសម្រាប់មេរៀន

| ល.រ | ខ្លឹមសារមេរៀន | ចំនួនម៉ោងសិក្សា | ផ្សេងៗ |
|---|---|---|---|
| ១ | ការរៀនគូសបន្ទាត់ | ០៦ ម៉ោង | **ត្រីមាសទី ១**<br>- ម៉ោងសរុប ១៣ម៉ x ១៣សប្តាហ៍ = ១៦៩ម៉<br>- ម៉ោងបង្រៀន ១៦២ម៉<br>- ម៉ោងនៅសល់ ០៧ម៉ |
| ២ | ចម្រៀងស្រះ | ០២ ម៉ោង | |
| ៣ | ស្រះនិស្ស័យ ២៣តួ | ១៦ ម៉ោង | |
| ៤ | ព្យញ្ជនៈ ៣៣តួ អមដោយចម្រៀង | ០៨ ម៉ោង | |
| ៥ | ព្យញ្ជនៈពួក "អ" ផ្សំនឹងស្រះ | ៥៨ ម៉ោង | |
| ៦ | ព្យញ្ជនៈពួក "អ៊" ផ្សំនឹងស្រះ | ៧២ ម៉ោង | |
| ៧ | បទចម្រៀងសារិកាកែវអើយ | ០២ ម៉ោង | **ត្រីមាសទី ២**<br>- ម៉ោងសរុប ១៣ម៉ x ១៣សប្តាហ៍ = ១៦៩ម៉<br>- ម៉ោងបង្រៀន ១៦៧ម៉<br>- ម៉ោងនៅសល់ ០០ម៉<br>(ចំពោះម៉ោងនៅសល់អាចដកម៉ោងពីត្រីមាសទី ៣ មកប្រើបាន) |
| ៨ | ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉ | ២៤ ម៉ោង | |
| ៩ | ប៊ ស៊ ហ៊ អ៊ | ១៥ ម៉ោង | |
| ១០ | មេសូត្ររត់មាត់ ម៉ែឪមានគុណ | ០២ ម៉ោង | |
| ១១ | ប្រកប | ៨១ ម៉ោង | |
| ១២ | ស្រះពេញតួ | ១០ ម៉ោង | |
| ១៣ | ព្យញ្ជនៈ និងជើង | ០៨ ម៉ោង | |
| ១៤ | ព្យញ្ជនៈផ្ញើជើង ក្ក ដល់ ឃ្ន ឃ្ល ឃ្វ | ២៧ ម៉ោង | |
| ១៥ | ចម្រៀង "ពេលដើរទៅសាលារៀន" | ០២ ម៉ោង | **ត្រីមាសទី ៣**<br>- ម៉ោងសរុប ១៣ម៉ x ១២សប្តាហ៍ = ១៥៦ម៉<br>- ម៉ោងបង្រៀន ១៣២ម៉<br>- ម៉ោងនៅសល់ ២៤ម៉ |
| ១៦ | ព្យញ្ជនៈផ្ញើជើង(ត) ច្បុ ច្ន ច្យ ដល់ចប់ | ៨១ ម៉ោង | |
| ១៧ | ព្យាង្គតម្រួត | ៤១ ម៉ោង | |
| ១៨ | អត្ថបទអំណាន | ០៨ ម៉ោង | |

- សរុបម៉ោងក្នុងកម្មវិធីសិក្សា : ១៣ម៉ x ៣៨សប្តាហ៍ = ៤៩៤ ម៉ោងសិក្សា
- សរុបម៉ោងបង្រៀន : = ៤៦៣ ម៉ោងសិក្សា
- សរុបម៉ោងសល់ / បម្រុង : = ៣១ ម៉ោងសិក្សា

*កំណត់សម្គាល់* ៖ ម៉ោងសិក្សាសរុបក្នុងកម្មវិធីសិក្សាមាន ៤៩៤ម៉ោង(ម៉ោងបង្រៀនសរុប ៤៦៣ម៉ោង នៅសល់ ៣១ម៉ោង ដែលគ្រូអាចបង្រៀនសាឡើងវិញ ឬធ្វើលំហាត់បន្ថែម)។

## ២ . វិធីសាស្ត្រ

មុននឹងបង្រៀនតួអក្សរ គ្រូត្រូវបញ្ជាក់ទីតាំង និងបង្រៀនគូសផ្នែកនៃតួអក្សរ(បន្ទាត់ និងខ្សែកោង) ជាមុនសិនដូចជា បន្ទាត់ផ្ដេក បញ្ឈរ កាច់ កោង មូល... ដើម្បីសម្របសម្រួលចលនាដៃទៅតាមភ្នែក ដែលកុមារមើលឃើញ។ កុមារតូចៗភាគច្រើន នៅមានការច្រឡំក្នុងការគូសពីឆ្វេងទៅស្ដាំ លើ ក្រោម មុខ ក្រោយ នៅឡើយ។ ចំណែកដៃរបស់គេ នៅមានការលំបាកក្នុងការចាប់កាន់ខ្មៅដៃ ឬដីសដើម្បីគូស ឬសរសេរ។ ដូច្នេះ នៅពេលបង្រៀនគូសបន្ទាត់ ឬសរសេរស្រៈ ព្យញ្ជនៈ គ្រូគប្បីយកចិត្តទុកដាក់ណែនាំសិស្សឱ្យបានច្បាស់លាស់អំពីការគូស និងសរសេរដែលត្រូវចាប់ផ្ដើម និងបញ្ចប់ ហើយតាមដានការគូស ឬសរសេររបស់សិស្សឱ្យបានហ្មត់ចត់តាមទម្រង់ ទំហំឱ្យបានច្បាស់លាស់ត្រឹមត្រូវ ដើម្បីកុំឱ្យគេគូស ឬ **សរសេរបញ្ច្រាស**។

បន្ទាប់ពីសិស្សមានមូលដ្ឋានគ្រឹះក្នុងការគូសបន្ទាត់ និងផ្នែកនៃតួអក្សររួចមក អ្នកគ្រូ លោកគ្រូអាចបង្រៀនតួអក្សរ (ស្រៈ ព្យញ្ជនៈ) ដោយធ្វើឱ្យពួកគេស្គាល់អក្សរនីមួយៗច្បាស់លាស់ ហើយចេះអាន និងសរសេរបានត្រឹមត្រូវ។ បន្ទាប់មកទៀត គ្រូប្រើប្រាស់ចំណេះដឹងបន្តទៅបង្រៀនព្យាង្គ ពោលគឺផ្សំព្យញ្ជនៈនីមួយៗនឹងស្រៈទាំង ២៣តួ។ ក្នុងការបង្រៀនព្យាង្គ(ការផ្សំព្យញ្ជនៈនឹងស្រៈ) គ្រូគប្បីប្រុងប្រយ័ត្នគ្រប់គ្រងសិស្ស និងតាមដានឱ្យបានច្បាស់លាស់ **ដើម្បីកុំឱ្យសិស្សរៀនតាមបែបចាំមាត់ តែពុំស្គាល់តួអក្សរច្បាស់លាស់**។ ដូច្នេះ ការរៀនអានបែបប្រកប និង**ការរៀនសរសេរជាការចាំបាច់បំផុត**។ បន្ទាប់មក ទើបបង្រៀនពាក្យ ល្បះ និងអត្ថបទ។ ដើម្បីទទួលបានជោគជ័យ គ្រូគប្បីយកចិត្តទុកដាក់លើការជួយសិស្សឱ្យចេះអាននិងសរសេរបានត្រឹមត្រូវ ដោយគួបផ្សំជាមួយការប្រើប្រាស់សម្ភារៈក្នុងការបង្រៀនពាក្យនិងល្បះផងដែរ។ វិធីនេះ ជួយឱ្យសិស្សមានមូលដ្ឋានរឹងមាំក្នុងការប្រកបពាក្យ។

ក្នុងការបង្រៀន គ្រូត្រូវចេះលើកទឹកចិត្តសិស្សដោយសរសើរគេ ហើយមិនត្រូវនិយាយបង្អាប់សិស្ស មិនធ្វើឥរិយាបថដែលនាំឱ្យគេខ្លាចមិនហ៊ានចូលរួម មិនហ៊ាននិយាយ តែត្រូវជួយពួកគេឱ្យមានសង្ឃឹម ហ៊ានសាកសួរ និងបង្កឱ្យមានបរិយាកាសសប្បាយរីករាយជាប្រចាំ ស្របតាមកម្មវិធីសាលាកុមារមេត្រី។

## ៣ . ការប្រើប្រាស់សម្ភារៈ

ក្នុងការបង្រៀន អ្នកគ្រូ លោកគ្រូគប្បីប្រើប្រាស់សម្ភារឧបទេស ពីព្រោះវាជាមធ្យោបាយមួយទាក់ទាញទឹកចិត្តសិស្សឱ្យចូលចិត្តរៀន មានការចងចាំ តាមរយៈការលើកបង្ហាញ និងចង្អុល ធ្វើឱ្យសិស្សបានសប្បាយ ហើយថែមទាំងយល់មេរៀនបានច្បាស់លាស់(យល់ន័យពាក្យ ល្បះ និងអត្ថបទ)ទៀតផង ។

សម្ភារៈដែលចាំបាច់បំផុតសម្រាប់បង្រៀនអាន និងសរសេរ គឺអក្សរចល័ត ប័ណ្ណពាក្យ តារាងស្រៈ ២៣តួ តារាងព្យញ្ជនៈ ៣៣តួ និងជើងព្យញ្ជនៈ តារាងស្រៈពេញតួ និងដីសពណ៌ ។ ក្រៅពីនេះ នៅមានរូបភាព និងវត្ថុជាក់ស្តែងផ្សេងទៀត តម្រូវទៅតាមពាក្យដែលត្រូវបង្រៀន ។

គ្រូអាចធ្វើបណ្ណពាក្យ សម្រាប់ប្រើប្រាស់ក្នុងការបង្រៀន ហើយអាចទុកប្រើប្រាស់បានយូរមិនអស់ប្រាក់កាសច្រើន ដោយកាត់ក្ដារឆ្នួន ឬក្រដាសកាតុង ឬក្រដាសឡាំង ដែលមានទំហំសមស្របសម្រាប់សរសេរពាក្យ១ព្យាង្គ ២ព្យាង្គ ឬ៣ព្យាង្គ ។ ប្រសិនបើក្រដាសឡាំង ត្រូវយកប្លាស្ទិចបិទពីលើឱ្យជិតសម្រាប់សរសេរជាមួយហ្វឺតអាចលុបវិញបាន ហើយទុកប្រើថ្ងៃក្រោយទៀត ។ ចំណែកសិស្ស ត្រូវមានក្ដារឆ្នួន ដីសជាចាំបាច់ និងអក្សរចល័តតូចៗ(ប្រសិនបើអាចរកបាន) ។

## ៤ . ការវាយតម្លៃ

នៅពេលបង្រៀនមេរៀនចប់ គ្រូត្រូវធ្វើការវាយតម្លៃ ដើម្បីវាស់ស្ទង់លទ្ធផលនៃការសិក្សារបស់សិស្ស ។ ការវាយតម្លៃត្រូវធ្វើជាប្រចាំ តាមដំណាក់ និងការប្រឡងប្រចាំខែ ប្រចាំឆមាស ។ ការវាយតម្លៃត្រូវសមស្របនឹងលទ្ធផលសិក្សាថ្នាក់ទី១ ដូចជាក្នុងការវាយតម្លៃការអាន ត្រូវឱ្យសិស្សអានស្រៈ ព្យញ្ជនៈ ស្រៈពេញតួ ពាក្យ ល្បះ អត្ថបទ ឬរៀបតួអក្សរតាមលំដាប់ ។ល ។ ចំណែកការវាយតម្លៃការសរសេរត្រូវឱ្យសិស្សចម្លង និងសរសេរអក្សរទាំងអស់នៃអក្ខរក្រម(ក ខ ... អ) **សរសេរតាមអាន** ពាក្យ និងកន្សោមពាក្យងាយៗ សរសេរចំណងជើងរូបភាព ។ល ។

## ៥ . ការដាក់កិច្ចការផ្ទះ

ការដាក់កិច្ចការផ្ទះ ជាមធ្យោបាយមួយសំខាន់ សម្រាប់ជួយសិស្សឱ្យឆាប់ចេះអាននិងសរសេរ និងជាទម្លាប់មួយឱ្យសិស្សចេះរៀនដោយខ្លួនឯង និងចូលចិត្តរៀន ។ គ្រូគប្បីដាក់កិច្ចការផ្ទះរាល់ថ្ងៃ ។

កិច្ចការផ្ទះសម្រាប់សិស្សថ្នាក់ទី១ អាចធ្វើបានតាមរូបភាពពីរយ៉ាង ៖

- ទីមួយ ឱ្យសិស្សអាន និងសរសេរអ្វីដែលគេបានរៀនរួចហើយឡើងវិញ ឱ្យសិស្សធ្វើលំហាត់ផ្សេងៗ ទាក់ទងនឹងមេរៀន ដែលបានរៀនរួចដើម្បីពង្រឹងចំណេះដឹង ។ នៅពេលរៀនតួអក្សរ ត្រូវឱ្យសរសេរជាអក្សរផ្ចង់ឱ្យស្អាត ហើយគ្រូកែនៅថ្ងៃបន្ទាប់ ។
- ទីពីរ ឱ្យសិស្សរៀនមេរៀនថ្មីត្រៀមទុកជាមុនដូចជាអាន និងសរសេរតួអក្សរ ឬពាក្យដែលនឹងត្រូវរៀននៅថ្ងៃបន្ទាប់ ។ ចំពោះពាក្យ ឬឃ្លាក្នុងសៀវភៅអាន-សរសេរថ្នាក់ទី១ ដែលគ្រូមិនបានបង្រៀននៅក្នុងថ្នាក់ ត្រូវដាក់កិច្ចការផ្ទះឱ្យសិស្សអានបន្ថែម ឬសរសេរនៅផ្ទះ ។

គ្រប់មេរៀន ត្រូវមានកិច្ចការផ្ទះ ។ គ្រូត្រូវដាក់កិច្ចការផ្ទះ ឱ្យសិស្សធ្វើចាប់ពីមេរៀនទី១ ឱ្យស្រប តាមការវិវត្តរបស់សិស្ស ដែលក្នុងនោះអាចឱ្យសិស្ស ៖

- រៀនគូសបន្ទាត់ឈរ ទ្រេត ផ្តេក ខ្សែកោង ...
- ចម្លងស្រះនិងព្យញ្ជនៈ ដែលបានរៀនរួចហើយ (ដាក់ក្នុងសៀវភៅកិច្ចការផ្ទះ)
- ចម្លងពាក្យនិងល្បះដែលបានរៀន
- បំពេញស្រះ ឬព្យញ្ជនៈ ដើម្បីបង្កើតពាក្យ (ក េ ក រ = កកេរ)
- សរសេរពាក្យតម្រូវទៅនឹងរូបភាព
- ភ្ជាប់រូបទៅនឹងពាក្យ (រូប ... ពាក្យ)

*កំណត់សម្គាល់ ៖*

- គ្រប់កិច្ចការអ្នកគ្រូ លោកគ្រូ ត្រូវត្រួតពិនិត្យ និងកែឱ្យបានទៀងទាត់ជាប្រចាំ និងប្រាប់កំហុសសិស្សឱ្យបានច្បាស់លាស់ ។
- គ្រប់មេរៀនត្រូវមានកិច្ចការផ្ទះជាប្រចាំ មិនចំពោះតែមេរៀនសាឡើងវិញនោះទេ ។

## ៦ . លំនាំបង្រៀន

### ៦.១ លំនាំបង្រៀន គូសបន្ទាត់ (ផ្នែកនៃតួអក្សរ)

- គ្រូគូសបន្ទាត់មួយ ដូចបន្ទាត់គំរូក្នុងសៀវភៅសិស្ស នៅលើក្ដារខៀនបង្ហាញសិស្ស ដោយគូសសញ្ញាព្រួញនៅក្បែរបន្ទាត់នោះផង ដើម្បីបង្ហាញទិសចាប់ផ្ដើម និងទិសបញ្ចប់ ហើយប្រាប់សិស្សឱ្យយល់សញ្ញាព្រួញនោះផង ។
- គ្រូគូសជាលើកទី ២ ដោយនិយាយបណ្ដើរ គូសបណ្ដើរ ។ *ឧទាហរណ៍* ខ្ញុំគូសពីឆ្វេងទៅស្ដាំ ។
- គ្រូនាំសិស្សគូសបន្ទាត់នោះក្នុងលំហ(លើខ្យល់) ដោយគ្រូបែរខ្នងបញ្ឆិតបន្តិច ហើយលើកដៃទៅមុខ ឱ្យសិស្សក្រោកឈរ ហើយធ្វើតាមគ្រូទាំងអស់គ្នា ។ គ្រូយកចង្អុលដៃគូសក្នុងខ្យល់ពីឆ្វេងទៅស្ដាំ ឱ្យសិស្សធ្វើតាមជាច្រើនសា ព្រមទាំងនិយាយផង ។
- ឱ្យសិស្សបើកសៀវភៅអាន-សរសេរ ហើយយកចង្អុលដៃគូសតាមបន្ទាត់នោះ តាមសញ្ញាព្រួញ ។
- គ្រូឱ្យសិស្សគូសបន្ទាត់នៅលើក្ដារឆ្នួនឱ្យបានច្រើនសា រួចពិនិត្យមើល ។ ប្រសិនបើសិស្សគូសខុស គ្រូត្រូវប្រាប់សិស្សឱ្យកែឡើងវិញរហូតដល់ត្រូវ រួចចម្លងដាក់សៀវភៅរៀងៗខ្លួន ។

*ចំណាំ ៖* គ្រូបង្រៀនគូសបន្ទាត់ផ្សេងទៀត ដោយធ្វើតាមលំនាំខាងលើ ។

### ៦.២ លំនាំបង្រៀនអាន និងសរសេរស្រៈនិស្ស័យ

- គ្រូបង្ហាញវត្ថុជាក់ស្ដែង ឬរូបភាពដែលមានសូរស្រៈ ដែលត្រូវរៀននៅក្នុងនោះ ឬគ្រូអាចហៅឈ្មោះសិស្ស ដែលមានសូរស្រៈនោះក៏បាន ។ *ឧទាហរណ៍* បង្រៀនស្រៈ " ា" គ្រូលើក កាទឹក បង្ហាញសិស្ស ឱ្យសិស្សប្រាប់ឈ្មោះវត្ថុនោះ ។
- គ្រូអានពាក្យ "កា"ដោយសង្កត់សូរសំឡេងលើស្រៈ " ា" ។ គ្រូបន្លឺស្រៈ [អា] ឱ្យសិស្សថាតាម ។
- គ្រូលើកស្រៈចល័ត " ា" បង្ហាញសិស្ស និងឱ្យសិស្សបន្លឺស្រៈ [អា] ម្នាក់ម្ដងៗ រួចមួយក្រុមម្ដង ទីបញ្ចប់ថាទាំងអស់គ្នា ។
- ឱ្យសិស្សចង្អុលបង្ហាញស្រៈ " ា" នៅក្នុងសៀវភៅរបស់គេ និងនៅក្នុងតារាងផ្សេងៗ ឬរកស្រៈ " ា" ក្នុងចំណោមស្រៈចល័ត ។
- គ្រូប្រាប់ពាក្យមួយចំនួនដែលមានសូរ " ា" ដូចជា តា ខា ហើយឱ្យសិស្សរកពាក្យផ្សេងទៀតដែលមានសូរ " ា" ។

*ចំណាំ* ៖ គ្រូបង្រៀនស្រៈផ្សេងទៀត ដោយធ្វើតាមលំនាំបង្រៀនស្រៈ "ា" ដែរ ។

- គ្រូសរសេរស្រៈ "ា" នៅលើក្ដារខៀន ដោយមានសញ្ញាព្រួញអមផង ។ គ្រូចង្អុលស្រៈ "ា" ឱ្យសិស្សអានម្នាក់ម្ដងៗ រួចអានទាំងអស់គ្នា ។
- គ្រូសរសេរស្រៈ "ា" ឱ្យសិស្សមើលព្រមទាំងនិយាយ ខ្ញុំគូសពីឆ្វេងទៅស្ដាំ ពីលើចុះក្រោម ។
- គ្រូនាំសិស្សសរសេរស្រៈលើខ្យល់ និងឱ្យសិស្សនិយាយបណ្ដើរ ។ គ្រូពិនិត្យក្រែងមានសិស្សគូសសញ្ញាបញ្ច្រាសទិស ។
- ឱ្យសិស្សយកចង្អុលដៃសរសេរស្រៈ តាមលំដាប់សញ្ញាព្រួញ ក្នុងសៀវភៅសិស្ស ។
- ឱ្យសិស្សសរសេរស្រៈ "ា" លើក្ដារឆ្នួន ។ គ្រូដើរពិនិត្យ និងកែលម្អសិស្សដែលសរសេរខុស ។
- ហៅសិស្ស ៣-៤នាក់ ឡើងសរសេរស្រៈនៅលើក្ដារខៀន និងបន្លឺសូរស្រៈនោះផង ។

*ចំណាំ* ៖ គ្រូបង្រៀនសរសេរស្រៈផ្សេងទៀត ដោយធ្វើតាមលំនាំបង្រៀនខាងលើ ។

*បញ្ជាក់* ៖ ប្រសិនបើក្នុងមួយពេលត្រូវបង្រៀនស្រៈលើសពីពីរ គ្រូគប្បីចង្អុល ឬហៅស្រៈឆ្លាស់គ្នាឱ្យសិស្សអាន និងសរសេរ ។ គ្រូមិនត្រូវបង្រៀនអាន ១ថ្ងៃ ហើយសរសេរ ១ថ្ងៃដាច់ពីគ្នាទេ ។ ការអាននិងសរសេរ ត្រូវតែបង្រៀនបន្តគ្នានៅថ្ងៃជាមួយគ្នា ឬអាននិងសរសេរជាមួយគ្នា ។

## ៦.៣ លំនាំបង្រៀនអានព្យញ្ជនៈ

- គ្រូបិទផ្ទាំងចម្រៀង កខ ... ឬចម្រៀងតួអក្សរវគ្គទី១នៅលើក្ដារខៀន ។ គ្រូច្រៀងចម្រៀងមួយវគ្គឱ្យសិស្សស្ដាប់ ព្រមទាំងចង្អុលចំៗតួអក្សរ ក ខ គ ឃ ង ។
- គ្រូ និងសិស្សច្រៀងជាមួយគ្នា ដោយគ្រូចង្អុលចំៗតួអក្សរផង ។
- គ្រូបន្លឺសូរ [ក] រួចឱ្យសិស្សចង្អុលតួអក្សរ ក នៅលើផ្ទាំងចម្រៀង ។ បន្ទាប់មក ឱ្យសិស្សចង្អុលអក្សរ ក នៅលើតារាងព្យញ្ជនៈ ៣៣តួ ។
- គ្រូបង្ហាញអក្សរចល័ត ក និងបន្លឺសូរ [ក] ។ ឱ្យសិស្សបន្លឺសូរ [ក] ជាបុគ្គល រួចជាក្រុមតាមជួរតុ រួចទាំងអស់គ្នា ។
- គ្រូសរសេរព្យញ្ជនៈ ក នៅលើក្ដារខៀន ដោយអក្សរធំៗ ។

*ចំណាំ* ៖ ចំពោះព្យញ្ជនៈផ្សេងទៀត គប្បីបង្រៀនដូចព្យញ្ជនៈ ក ដែរ ។

- គ្រូអានព្យញ្ជនៈមួយម្ដងៗ ដោយចង្អុលចំៗតួអក្សរ ឱ្យសិស្សថាតាមជាក្រុមតូចៗ ។

- គ្រូហៅសិស្សឡើងអានម្នាក់ម្ដងៗ ដោយចង្អុលឱ្យចំតួអក្សរនីមួយៗ ។
- គ្រូចង្អុលព្យញ្ជនៈឆ្លាស់គ្នាឱ្យសិស្សអាន រួចឱ្យអានបញ្ច្រាស ដើម្បីឱ្យសិស្សចំណាំតួអក្សរបានច្បាស់ ។ គ្រូអានហើយ ឱ្យសិស្សឡើងចង្អុល ។
- គ្រូហៅសិស្សឡើងបង្ហាញព្យញ្ជនៈចល័តមួយម្ដងៗ រហូតដល់ចប់ ។
- ឱ្យសិស្សអានព្យញ្ជនៈ នៅក្នុងសៀវភៅអាន-សរសេរថ្នាក់ទី១ របស់គេជាដៃគូ ដោយម្នាក់ចង្អុលឆ្លាស់ចុះឆ្លាស់ឡើង ហើយម្នាក់ទៀតអាន រួចប្ដូរវេនគ្នា ។

*កំណត់សម្គាល់* ៖ ក្នុងពេលនេះ មិនទាន់តម្រូវឱ្យសិស្សរៀនសរសេរ ក ខ ទេ គឺគ្រាន់តែអានប៉ុណ្ណោះ ។

## ៦.៤ លំនាំបង្រៀនអាន និងសរសេរព្យញ្ជនៈពួក អ ផ្សំនឹងស្រះ

### ក. ការបង្រៀនអានព្យាង្គ (ក កា កិ កី កឹ កឺ ...កោះ)

- គ្រូលើកអក្សរចល័ត ក រួចសួរសិស្ស តើនេះជាអក្សរអ្វី ? គ្រូបង្ហាញស្រៈ ា រួចសួរសិស្ស តើនេះជាស្រៈអ្វី? គ្រូយក ក ផ្សំនឹងស្រៈ ា គ្រូអានជាគំរូ ក ា កា រួចឱ្យសិស្សអានតាម ។ គ្រូសរសេរ កា នៅលើក្ដារខៀន ។
- គ្រូបង្រៀនព្យញ្ជនៈ ក នឹងស្រៈផ្សេងទៀតរហូតដល់ស្រៈ ោះ ដោយធ្វើតាមលំនាំបង្រៀន ក និងស្រៈ ា ដែរ ។
- គ្រូចង្អុល និងអានព្យាង្គមួយម្ដងៗ ឱ្យសិស្សស្ដាប់ដូចខាងក្រោម ៖

  ក ា កា , ក ិ កិ , ក ី កី ... ក ុំ កុំ , ក ំ កំ , ក ាំ កាំ

  ក ះ កះ , ក ុះ កុះ , ក េះ កេះ , ក ោះ កោះ ។
- គ្រូនិងសិស្សអានជាមួយគ្នាពីដើមដល់ចប់ ដោយគ្រូចង្អុលតាមលំដាប់ រួចបញ្ច្រាសមកវិញ រួចឆ្លាស់ចុះឡើង ។
- ឱ្យសិស្សអានឱ្យបានច្រើនដង រហូតដល់ចាំមាត់ជាបុគ្គល ជាក្រុមតូច និងទូទាំងថ្នាក់ ។
- បន្ទាប់មក គ្រូចង្អុល និងអាន ដោយមិនបាច់ប្រកប ឱ្យសិស្សថាតាមដូចខាងក្រោម ៖

  ក កា កិ កី ...............កុំ កំ កាំ កះ កុះ កេះ កោះ ។
- គ្រូនិងសិស្សអានជាមួយគ្នាពីដើមដល់ចប់ ដោយគ្រូជាអ្នកចង្អុល ។

- ឱ្យសិស្សអានជាក្រុមតាមជួរតុ រួចអានម្នាក់ម្តងៗ ។ ឱ្យសិស្សអានច្រាសមកវិញ ។ កោះ កេះ កុះ ...កា ។
- ឱ្យសិស្សអានសៀវភៅរបស់ពួកគេជាដៃគូ រួចជាបុគ្គល ។

*ចំណាំ ៖* ចំពោះព្យញ្ជនៈផ្សំនឹងស្រះផ្សេងទៀត គ្រូគប្បីបង្រៀនតាមលំនាំការបង្រៀនខាងលើនេះដែរ ។

*កំណត់សម្គាល់ ៖*

- គ្រូអាចចម្លងព្យញ្ជនៈផ្សំស្រះ ក កា កិ កី ...កោះ ដាក់លើក្ដារខៀនទុកមុនក៏បាន ប៉ុន្តែត្រូវបង្រៀនការផ្សំ ដោយប្រើអក្សរចល័តមួយម្ដងៗ មុនឱ្យសិស្សអាន ។
- នៅពេលសិស្សអានការផ្សំបានរត់មាត់ហើយ មេរៀនក្រោយៗគ្រូមិនគប្បីប្រើពេលយូរក្នុងការផ្សំព្យញ្ជនៈនឹងស្រះ ដូចពេលមុនទេ ។

## ខ. ការបង្រៀនពាក្យ

- គ្រូបង្ហាញសម្ភារៈជាក់ស្ដែង រូបភាព ធ្វើកាយវិការ លើកឧទាហរណ៍ ធ្វើការប្រៀបធៀប ឬសួរសំណួរតម្រូវទៅតាមប្រភេទពាក្យ(នាម គុណនាម កិរិយា) ដើម្បីបង្កើតពាក្យដែលត្រូវរៀន ។ ឱ្យសិស្សថាពាក្យនោះ ៣-៤នាក់ ។
- គ្រូបង្ហាញប័ណ្ណពាក្យ រួចសរសេរពាក្យលើក្ដារខៀនឱ្យសិស្សអានជាបុគ្គល ។
- គ្រូនាំសិស្សបំបែកពាក្យ ដោយសួរសិស្សថា តើពាក្យ ...... មានព្យញ្ជនៈ និងស្រះអ្វីខ្លះ ? គ្រូប្រើអក្សរចល័តបំបែកពាក្យ ឱ្យសិស្សមើល ។ ***ឧទាហរណ៍*** កា = ក ា , កី = ក ី , កួរ = ក ួ រ
- នាំសិស្សផ្សំព្យញ្ជនៈនឹងស្រះ ឱ្យសិស្សថាតាម ។ ***ឧទាហរណ៍*** ក ា ⟶ កា , ក ី ⟶ កី

*ចំណាំ ៖* ឯការបង្រៀនពាក្យដទៃ ធ្វើដូចបង្រៀនពាក្យ "កា" ដែរ ។
- ឱ្យសិស្សអានពាក្យនីមួយៗឡើងវិញ ដោយប្រកប ។ ***ឧទាហរណ៍*** កា = ក ា , កី = ក ី ...
- បង្រៀនពាក្យពីរព្យាង្គ "កកោះ" ដោយបង្ហាញសម្ភារៈ រួចបង្ហាញពាក្យ ។ បង្ហាញការបំបែកពាក្យជាព្យាង្គ កកោះ = ក កោះ និងផ្សំព្យាង្គ ។ ***ឧទាហរណ៍*** ក កោះ ⟶ កកោះ ។
- គ្រូអានពាក្យ កកោះ ។ ក ក េាះ កោះ កកោះ សិស្សអានពាក្យជាមួយគ្រូ រួចឱ្យសិស្សអាន ។
- គ្រូចង្អុលព្យាង្គ ពាក្យឆ្លាស់គ្នាឱ្យសិស្សអានជាបុគ្គល ឬគ្រូអានហៅសិស្សចង្អុល ។
- ឱ្យសិស្សរៀបអក្សរចល័តជាពាក្យ តាមការកំណត់របស់គ្រូ តាមក្រុមតូចៗ ។
- ឱ្យសិស្សអានព្យាង្គ ពាក្យ ល្បះនៅក្នុងសៀវភៅជាបុគ្គល ជាដៃគូឬក្រុម ដោយប្តូរវេនគ្នាចង្អុល ។

### គ. ការបង្រៀនល្បះ

- គ្រូបង្ហាញផ្ទាំងរូបភាព បំផុសសំណួរ រឿងនិទាន កាយវិការ ដើម្បីបង្កើតល្បះដែលត្រូវបង្រៀន ។
- គ្រូចម្លងល្បះ ដាក់លើក្ដារខៀន ។ គ្រូអាចបំបែកល្បះជាផ្នែកតូចៗ(ពាក្យ) ដើម្បីឱ្យសិស្សងាយអាន ។ *ឧទាហរណ៍* កុំ កេះ កៃ ។
- គ្រូសួរសិស្ស តើល្បះនេះមានប៉ុន្មានពាក្យ ? (៣ពាក្យ) តើពាក្យ "កុំ" មានអក្សរអ្វីខ្លះ ? ...
- ឱ្យសិស្សអានពាក្យនីមួយៗ ដោយប្រកបដូចខាងក្រោម ៖

  ក អុំ កុំ , ក អេះ កេះ , ក អៃ កៃ , កុំ កេះ កៃ ។
- ឱ្យសិស្សផ្សំបណ្ណពាក្យជាល្បះ តាមក្រុមតូចៗ រួចអានល្បះនោះ ។

### ឃ. ការបង្រៀនសរសេរព្យញ្ជនៈ ព្យាង្គ និងពាក្យ

- គ្រូសរសេរព្យញ្ជនៈ ក ឱ្យធំៗនៅលើក្ដារខៀន ដោយគូសសញ្ញាព្រួញអមផង ។
- គ្រូសរសេរព្យញ្ជនៈ ក ដោយគូសគំនូសម្ដងៗ តាមលំដាប់សញ្ញាព្រួញ ឱ្យសិស្សសង្កេត ព្រមទាំងនិយាយផង ។ ខ្ញុំគូសពីក្រោមឡើងលើ គូសពីឆ្វេងទៅស្ដាំ រួចគូសពីលើចុះក្រោម បន្ទាប់មក ដាក់សក់ ។
- គ្រូឱ្យសិស្សសរសេរ ក លើខ្យល់តាមគ្រូ ព្រមទាំងនិយាយ ។ គ្រូពិនិត្យ និងកែតម្រូវ ។
- គ្រូឱ្យសិស្សសរសេរ ក លើក្ដារឆ្នួន គ្រូពិនិត្យ និងកែលម្អ ។

  *ចំណាំ* ៖ គ្រូគប្បីដើរពិនិត្យពេលសិស្សសរសេរ ដើម្បីចៀសវាងការសរសេរបញ្ច្រាសទិស ។
- គ្រូហៅសិស្ស ៤-៥នាក់ សរសេរលើក្ដារខៀន ។
- គ្រូហៅព្យាង្គ ពាក្យខ្លះ ឱ្យសិស្សសរសេរ ។ ដំបូង គ្រូឱ្យសិស្សធ្វើអក្ខរវិញ្ញាស ដោយសួរ ៖ "តើពាក្យ កី សរសេរដូចម្ដេច ? " ។ គ្រូឱ្យសិស្សថា កី សរសេរ ក ស្រៈ ី ខ្ញុំអានថា កី ។ កក្កូរ សរសេរ ក ក ស្រៈ ូ និង រ ខ្ញុំអានថា កក្កូរ សរសេរពាក្យនេះ លើក្ដារឆ្នួននិងក្ដារខៀន ។

## ៦.៥ លំនាំបង្រៀនអាន និងសរសេរព្យញ្ជនៈពួក អ៊ ផ្សំនឹងស្រៈ

លំនាំបង្រៀនអាន និងសរសេរព្យញ្ជនៈពួក [អ៊] ផ្សំនឹងស្រៈ គប្បីធ្វើតាមលំនាំបង្រៀនព្យញ្ជនៈពួក [អ] ផ្សំនឹងស្រៈដែរ គ្រាន់តែការអានមានសូរសំឡេងខុសគ្នាដូចខាងក្រោម ៖

ដំបូង គ្រូប្រាប់សិស្សថា ស្រៈ ា ិ ី .... ោះ ។ កាលណាប្រើជាមួយព្យញ្ជនៈពួក [អ៊] ដូចជា គ ឃ ង ... ត្រូវដូរសំឡេងទៅជា អ៊ា អ៊ិ អ៊ី អ៊ឹ អ៊ឺ អ៊ុ អ៊ូ អ៊ួ អ៊ើ អ៊ឿ អ៊ៀ អ៊េ អ៊ែ អ៊ៃ អ៊ោ អ៊ៅ អ៊ុំ អ៊ំ អ៊ាំ អ៊ះ អ៊ុះ អ៊េះ អ៊ោះ ។ គ្រូគប្បីនាំសិស្សអាន អ៊ អ៊ា .....អ៊ោះ សិន ។

គ អ៊ា គា　　គ អ៊ិ គិ　　គ អ៊ី គី　　គ អ៊ឹ គឹ　　គ អ៊ឺ គឺ　　គ អ៊ុ គុ

គ អ៊ូ គូ　　គ អ៊ួ គួ　　គ អ៊ើ គើ　　គ អ៊ឿ គឿ　　គ អ៊ៀ គៀ　　គ អ៊េ គេ

គ អ៊ែ គែ　　គ អ៊ៃ គៃ　　គ អ៊ោ គោ　　គ អ៊ៅ គៅ　　គ អ៊ុំ គុំ(គុម)　　គ អ៊ំ គំ

គ អ៊ាំ គាំ(គ័ម)　　គ អ៊ះ គះ　　គ អ៊ុះ គុះ　　គ អ៊េះ គេះ　　គ អ៊ោះ គោះ ។

គា គិ គី គឹ គឺ គុ គូ គួ គើ គឿ គៀ គេ គែ គៃ គោ គៅ គុំ គំ គាំ គះ គុះ គេះ គោះ ។

## ៦.៦ លំនាំបង្រៀនអក្សរមានសញ្ញាមូសិកទន្ត ឬ ធ្មេញកណ្ដុរ(") ឬសញ្ញា(អ ) ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉

- គ្រូយកផ្ទាំងព្យញ្ជនៈ ដាក់ផ្គុំគ្នា ។
- គ្រូចង្អុលអក្សរ ង ញ ប ម យ រ វ មួយតួម្ដងៗ រួចសួរសិស្សថា តើនេះជាអក្សរអ្វី ?

| | |
|---|---|
| ង | ង៉ |
| ញ | ញ៉ |
| ប | ប៉ |
| ម | ម៉ |
| យ | យ៉ |
| រ | រ៉ |
| វ | វ៉ |

- គ្រូចង្អុលអក្សរមួយម្ដងៗ និងបញ្ចេញសំឡេងឱ្យសិស្សស្ដាប់ និងថាតាម ។ គ្រូនិងសិស្សអាន ជាមួយគ្នា រួចសិស្សអានខ្លួនឯងជាក្រុមតូចៗ ។ *ឧទាហរណ៍* ង ង៉ ។

- គ្រូសួរថា គូទី១ ក្នុងតារាងខាងលើ មានសំឡេងខុសគ្នាដូចម្ដេច ? តើវាខុសគ្នា ដោយសារអ្វី ? ដោយសារមានសញ្ញា ( ៉ ) គ្រូប្រាប់សិស្សថា សញ្ញា ( ៉ ) គេហៅថាសញ្ញា (អ) ឬធ្មេញកណ្ដុរ ឬមូសិកទន្ត។ កាលណាវាដាក់លើ ង ទៅជា ង៉ , ញ ទៅជា ញ៉ (មានសំឡេង អ) កាលណាវានៅជាមួយស្រៈ ិ ី ឹ ឺ ើ ាំ វាដូររាងជាបុកជើង ុ វិញ។

  ***ឧទាហរណ៍*** ៖ ញ៉ អាំ ញ៉ាំ , ចា ប៉ ី ចាប៊ី។
- គ្រូនាំសិស្សអាន ង សម្លាប់ពីរ ង៉ , ញ សម្លាប់ពីរ ញ៉ ...ឱ្យសិស្សថាតាមម្នាក់ម្ដងៗ រួចជាក្រុម ទូទាំងថ្នាក់។
- គ្រូនាំសិស្សអានព្យាង្គ ង៉ា ង៉ិ ង៉ី ង៉ឹ ង៉ឺ ..................... ង៉ោះ ដោយបញ្ចេញសំឡេង ង៉ អា ង៉ា ង៉ អិ ង៉ិ ............ង៉ អោះ ង៉ោះ។ រួច ង៉ា ង៉ិ ង៉ី ..........ង៉ោះ។
- គ្រូបង្រៀនពាក្យ ដោយនាំសិស្សប្រកបដូចពេលរៀនពាក្យមុនៗដែរ។

## ៦.៧ លំនាំបង្រៀនសញ្ញាត្រីស័ព្ទ ឬ សញ្ញាសក់ក ( ៊ ) ឬ សញ្ញា (អ៊)

សូមអ្នកគ្រូ លោកគ្រូបង្រៀនតាមលំនាំបង្រៀនមូសិកទន្ត ឬធ្មេញកណ្ដុរ។

## ៦.៨ លំនាំបង្រៀនព្យញ្ជនៈប្រកបនឹង □ក □ក់

### ក. ពាក្យពួក (អ)

- គ្រូបង្ហាញអក្សរចល័ត ក រួចសួរថា តើនេះជាអក្សរអ្វី ? គ្រូយកអក្សរ ក មួយទៀតមកបង្ហាញ រួចសួរដូចមុន។
- គ្រូដាក់ផ្ទឹមគ្នា ក ក រួចអាន ក និង ក កក ឱ្យសិស្សថាតាមម្នាក់ម្ដងៗ ជាក្រុម និងទាំងអស់គ្នា។ គ្រូសរសេរពាក្យ កក លើក្ដារខៀន។ គ្រូបង្ហាញអក្សរ ខ រួចសួរដូចមុន។ គ្រូយកព្យញ្ជនៈ ក មកដាក់ជាប់នឹងព្យញ្ជនៈ ខ រួចឱ្យសិស្សអានថា ខ និង ក ខក រួចគ្រូសរសេរពាក្យ ខក នៅលើក្ដារខៀន។ បន្ទាប់មក ធ្វើដូចគ្នាចំពោះពាក្យ បក សក។
- គ្រូយកអក្សរ ក មកដាក់ជាមួយ ក ឱ្យសិស្សអានម្ដងទៀត រួចគ្រូដាក់សញ្ញាបន្តក់ពីលើ ក(តួប្រកប) ហើយនាំសិស្សអាន ក និង ក កក បន្តក់មួយ កក់។ ខ និង ក ខក បន្តក់មួយ ខក់។ ប្រាប់សិស្សថាសញ្ញានេះ ( ់ ) គេហៅថា បន្តក់។

- គ្រូបង្ហាញអក្សរ ក ា ក រួចប្រកប ក ា កា និង ក កាក , រួច ខ ា ខា និង ក ខាក ។
- គ្រូដូរពី ក ខាងចុងទៅជា ក់ ហើយនាំសិស្សអាន ៖ ក ា កា និង ក កាក បន្តក់មួយ កាក់ ។ ខ ា ខា និង ក ខាក បន្តក់មួយ ខាក់ ... ។
- គ្រូអានពាក្យឱ្យសិស្សស្តាប់ និងថាតាមទាំងអស់គ្នា ៖

  *ឧទាហរណ៍ :*

  - ក និង ក កក , ក និង ក កក បន្តក់មួយ កក់
  - ក ា កា និង ក កាក , ក ា កា និង ក កាក បន្តក់មួយ កាក់
  - ផ ី ផី និង ក ផីក ...
  - រួចឱ្យសិស្សអាន កក កក់ ខក ខក់ កាក កាក់ ផីក ... ។
- ហៅសិស្សអានជាក្រុមតូចៗ រួចអានម្នាក់ម្តងៗ ឱ្យបានច្រើនសា ដើម្បីឱ្យសិស្សចេះស្ទាត់ ។ (ចំពោះពាក្យមានន័យ គ្រូប្រើសម្ភារៈ រូបភាព ឬកាយវិការ ...ដើម្បីបំផុសឱ្យបានពាក្យនោះ និងឱ្យសិស្សយល់ន័យពាក្យ) ។
- គ្រូនាំសិស្សអានពាក្យទាំងនោះ តាមរបៀបអានខាងលើ ។ បន្ទាប់មក គ្រូនាំសិស្សអានល្បះដូចការអានល្បះក្នុងមេរៀនមុនៗដែរ ។
- ឱ្យសិស្សអានជាដៃគូ ដោយប្រើសៀវភៅរបស់ពួកគេ និងប្តូរវេនគ្នាចង្អុល ។
- គ្រូចង្អុលពាក្យចោះៗ ឱ្យសិស្សអាន និងសរសេរលើក្តារឆ្នួន ។
- គ្រូហៅសិស្សសរសេរពាក្យលើក្តារខៀន ប្រណាំងគ្នាមួយគូៗ ។

## ខ. ពាក្យពួក ( អ៊ )

របៀបបង្រៀនពាក្យប្រកបពួក [អ៊] គប្បីបង្រៀនដូចពួក [អ] គ្រាន់តែគ្រូនាំសិស្សអានតាមសូរសំឡេងពួក [អ៊] ដូចជា ៖

- គ និង ក គក , ល និង ក លក ....
- គ និង ក គក បន្តក់មួយ គក់ , ល និង ក លក បន្តក់មួយ លក់
- គ អ៊ា គា និង ក គាក , គ អ៊ា គា និង ក គាក បន្តក់មួយ គាក់
- ល អ៊ា លា និង ក លាក , ល អ៊ា លា និង ក លាក បន្តក់មួយ លាក់ ... ។

## ៦.៩ លំនាំបង្រៀនស្រះពេញតួ

ការបង្រៀនស្រះពេញតួ គប្បីផ្ដើមចេញពីរូបភាព ឬសម្ភារៈផ្សេងៗ ដើម្បីបង្កើតពាក្យ ។ *ឧទាហរណ៍* បង្ហាញរូបភាពអគារ បង្ហាញពាក្យអគារ រួចបំបែកពាក្យជាពីរព្យាង្គ ។ *ឧទាហរណ៍* អគារ = អ គារ នាំសិស្សអានថា [អៈគា] អគារ ។ បង្ហាញស្រះពេញតួចល័ត អ នាំសិស្សអាន អៈ ។ គ្រូបង្រៀនពាក្យផ្សេងទៀត ដោយធ្វើដូចស្រះពេញតួ អ ដែរ ។ គ្រូអានស្រះពេញតួ រួចអានពាក្យឱ្យសិស្សស្ដាប់ ។ គ្រូនិងសិស្សអានជាមួយគ្នា រួចសិស្សអាន ។ គ្រូហៅពាក្យឱ្យសិស្សសរសេរ ជាបន្តបន្ទាប់គ្នា ។

## ៦.១០ លំនាំបង្រៀនអាន និងសរសេរព្យញ្ជនៈផ្ញើជើង (ពួក អ និង អ៊ )

- គ្រូបង្ហាញអក្សរ ក ចល័ត រួចសួរ តើនេះជាអក្សរអ្វី ? គ្រូបង្ហាញជើង ្ល រួចសួរនេះជាអ្វី ? គ្រូយក ក ដាក់លើជើង ្ល រួចឱ្យសិស្សអានឱ្យស្ដាប់ ឬគ្រូអាន ។ គ្រូឱ្យសិស្សថាតាមទាំងអស់គ្នា ។ សិស្សថាជាក្រុមតូចៗ ។
- គ្រូយកស្រះ ា ិ ី ឹ ឺ មកផ្សំជាមួយ ក្ល មួយម្ដងៗ ហើយអានឱ្យសិស្សស្ដាប់ ឱ្យសិស្សថាជាក្រុម ឬជាបុគ្គល ។

  *ចំណាំ ៖* ចំពោះព្យញ្ជនៈផ្សំនឹងជើងផ្សេងទៀត គ្រូគប្បីធ្វើដូច ក ផ្សំនឹងជើង ្ល ដែរ ។
- គ្រូលើករូបភាព ឬរកឧទាហរណ៍បង្ហាញសិស្ស ដើម្បីបង្រៀនពាក្យ ក្បាល ...ឱ្យសិស្សប្រាប់ឈ្មោះរូបភាព ។ គ្រូបង្ហាញប័ណ្ណពាក្យ និងអានពាក្យឱ្យសិស្សថាតាម ។
- គ្រូនាំសិស្សវិភាគពាក្យដោយសួរសិស្សថា តើពាក្យ ក្បាល មានអក្សរអ្វីខ្លះ ? គ្រូសរសេរពាក្យនៅលើក្ដារខៀន ។ *ឧទាហរណ៍* ក្បាល = ក្ប ា ល (ក្បាល មាន ក្ប ស្រះ ា និង ល)
- គ្រូនាំសិស្សផ្សំពាក្យ ៖ ក្ប ា ល ⟶ ក្បាល ។ នាំសិស្សអាន ក្ប ា និង ល ក្បាល ។
- គ្រូសួរសិស្ស តើ ក្ប មានអក្សរអ្វីខ្លះ ? (ក្ប មាន ក ជើង ្ប) ប្រាប់សិស្សថាជើង ប ( ្ប) ក៏មានសូរសំឡេងដូចព្យញ្ជនៈ ប ដែរ ។ ប្រាប់សិស្សថា ការអានព្យញ្ជនៈផ្ញើជើង គេត្រូវអានព្យញ្ជនៈខាងលើមុន ក ហើយផ្សំសូររបស់ជើងព្យញ្ជនៈខាងក្រោម ្ប ទៅជា ក្ប ។
- គ្រូអានព្យាង្គឱ្យសិស្សស្ដាប់ ក ជើង ្ប ក្ប ក ជើង ្ប ក្ប ក្ប ា ក្បា ក ជើង ្ប ក្ប ក្បិ ... រួចឱ្យសិស្សអានជាក្រុម ជាបុគ្គល ។

- គ្រូនិងសិស្សអានពាក្យជាមួយគ្នា ។ *ឧទាហរណ៍* ក ជើង ្ល ក្ល ក្ល អា ក្លា ក្លា និង ល ក្លាល ។ ***ចំណាំ ៖*** ចំពោះពាក្យផ្សេងទៀត គ្រូបង្រៀនដូចពាក្យ **ក្លាល** ដែរ ។
- គ្រូហៅពាក្យឱ្យសិស្សចង្អុល និងចង្អុលពាក្យឱ្យសិស្សអាន ។
- ហៅសិស្សពូកែឡើងអានព្យាង្គ និងពាក្យនៅក្ដារខៀន រួចឱ្យសិស្សអាននៅក្នុងសៀវភៅតាមក្រុមតូចៗ ។
- គ្រូហៅពាក្យឱ្យសិស្សសរសេរ នៅលើក្ដារឆ្នួន ។ គ្រូហៅសិស្សឱ្យឡើងសរសេរ លើក្ដារខៀន ។

## ៦.១១ លំនាំបង្រៀនអាន និងសរសេរពាក្យព្យាង្គតម្រួត

- គ្រូចម្លងចំណងជើងមេរៀន (ង្ក ង្ខ ...) ដាក់លើក្ដារខៀន ។
- គ្រូបង្ហាញសម្ភារៈជាក់ស្ដែង ឬរូបភាពដើម្បីបំផុសរកពាក្យ ។
- គ្រូសរសេរពាក្យនោះនៅក្ដារខៀន ដោយប្រើដីសពណ៌ ។ គ្រូអានពាក្យនោះ ឱ្យសិស្សថាតាមក្រុមតូចៗ ។ សួរសិស្សថា តើពាក្យ .....មានអក្សរអ្វីខ្លះ ?
- គ្រូសរសេរវិធីបំបែកពាក្យនៅក្ដារខៀន ឬលើផ្ទាំងក្រដាសតាមលំនាំខាងក្រោម ជាអក្សរធំៗ ។ គ្រូអាចប្រើពណ៌ក្រហម សម្រាប់បន្តក់ និងជើងព្យញ្ជនៈ ឬប្រើប័ណ្ណអក្សរចល័ត ។ *ឧទាហរណ៍* **អង្ករ = អង់ ករ** ប្រាប់សិស្សថា **អង្ករ** ជាពាក្យ ២ព្យាង្គ ដែលសរសេរត្រួតគ្នា ឬហៅថាព្យាង្គតម្រួត ។
  - ព្យាង្គទី ១ **អង់**
  - ព្យាង្គទី ២ **ករ**
  - **អ** និង **ង** ត្រូវអានថា **អង់** ជើង ្ក ត្រូវអានដូច ក ដែរ ជើង ្ក និង **រ** ត្រូវអានដូច ក និង **រ** គឺ ក ។ ដូច្នេះ អង្ករ ត្រូវអានថា **អ** និង **ង** **អង់** ក និង **រ** ក **អង្ករ** ។
- គ្រូនាំសិស្សអានពាក្យព្យាង្គតម្រួត ឬផ្ញើជើងដូចខាងក្រោម ៖
  - **ង្ក ង្ខ ង្គ** អានថា **ង** ជើង ក , **ង** ជើង *ខ* , **ង** ជើង គ ...
  - **អ** និង **ង** **អង់** ក និង **រ** ក **អង្ករ**
  - **កង្កែប = ក** និង **ង** **កង់** ក **អែ** *កែ* និង **ប** *កែប* **កង្កែប**
- ហៅសិស្សឡើងអានម្ដងម្នាក់ ឬអានជាក្រុមតូចៗ ។

- ហៅពាក្យឱ្យសិស្សធ្វើអក្ខរាវិរុទ្ធ និងសរសេរលើក្ដារខៀន ។
- ចំពោះ ៖ ង្គ្រ ញ្ជ្រ ន្ត្រ ....... ត្រូវអានដូចខាងក្រោម ៖
  - ង ជើង ក ជើង រ , ញ ជើង ជ ជើង រ , ន ជើង ត ជើង រ
  - អង្គ្រង អានថា អ និង ង អង់ ក ជើង ្រ ក្រ ក្រ និង ង ក្រង = អង្គ្រង ។
  - កន្ត្រៃ អានថា ក និង ន កន់ ត ជើង ្រ ត្រ ត្រ អៃ ត្រៃ = កន្ត្រៃ ។

*ចំណាំ ៖*

១. គ្រប់មេរៀន បើមានពាក្យ ឬឃ្លាច្រើន គ្រូមិនត្រូវបង្រៀនទាំងអស់នោះទេ គឺដកយកតែពាក្យ ឬឃ្លា ដែលសមស្របនឹងពេលវេលាមកបង្រៀន ឯពាក្យ ឬឃ្លានៅសល់ ត្រូវដាក់ជាកិច្ចការផ្ទះ ឬអំណានបន្ថែម ។

២. គ្រប់មេរៀន មិនត្រូវបង្រៀនអាន និងសរសេរនៅថ្ងៃផ្សេងៗគ្នាទេ គឺត្រូវបង្រៀននៅថ្ងៃជាមួយគ្នា ។ គ្រូអាចបង្រៀនអាន១ម៉ោង រួចបង្រៀនសរសេរ ១ម៉ោង ជាប់គ្នា ឬបង្រៀនពាក្យនីមួយៗអាន និងសរសេរជាមួយគ្នា ។

## ៦.១២ លំនាំបង្រៀនអំណានអត្ថបទ

### ក. លំណែនាំ

- ដើម្បីអានអត្ថបទបានល្អ មិនទាក់ មិនរដាក់រដុប និងយល់ន័យនៃអត្ថបទសិស្សត្រូវ ៖
  - ទី១ ៖ ស្គាល់តួអក្សរ ឱ្យបានច្បាស់លាស់
  - ទី២ ៖ ផ្អែកលើពាក្យ ឃ្លា និងល្បះខាងដើម ដើម្បីស្មានពាក្យដែលនៅបន្តបន្ទាប់
  - ទី៣ ៖ ស្វែងយល់ន័យ នៃល្បះនីមួយៗ
  - ទី៤ ៖ ស្គាល់សញ្ញាសម្គាល់ សញ្ញាវណ្ណយុត្ត( ។,?...)ក្នុងអត្ថបទ ទើបអាចលើកដាក់សំឡេងបានសមស្រប ទៅតាមន័យរបស់អត្ថបទ ។
- គ្រូមិនត្រូវទម្លាប់សិស្ស ឬមិនត្រូវឱ្យសិស្សអានបង្អួសនោះទេ ។

### ខ. លំនាំបង្រៀន

- គ្រូចម្លងអត្ថបទដាក់លើក្ដារខៀន ឬប្រើអត្ថបទក្នុងសៀវភៅសិស្ស
- គ្រូឱ្យសិស្សអានអត្ថបទ ដោយស្ងៀមស្ងាត់

- គ្រូឱ្យសិស្សប្រាប់ពាក្យពិបាក ពាក្យមិនធ្លាប់ស្គាល់ និងពាក្យមិនទាន់យល់ន័យ រួចស្រង់ពាក្យពិបាកទាំងនោះដាក់លើក្ដារខៀន
- គ្រូអានពាក្យពិបាក ឱ្យសិស្សថាតាម និងធ្វើអក្ខរាវិរុទ្ធ
- គ្រូពន្យល់ពាក្យពិបាក ដោយប្រើរូបភាពជាជំនួយសម្រាប់ពាក្យរូបី ធ្វើកាយវិការ ឬលើកឧទាហរណ៍បញ្ជាក់ ។ល។ ដើម្បីជួយឱ្យសិស្សយល់ន័យនៃពាក្យទាំងនោះ កាន់តែច្បាស់ ។
- គ្រូអានជាគំរូ ។ គ្រូនិងសិស្សអានជាមួយគ្នាមួយល្បះម្ដងៗ រហូតដល់ចប់ ដោយមានការអានតាមលំនាំផ្អាក និងដាក់សំឡេងនៅពេលបញ្ចប់ល្បះនីមួយៗ និងនៅត្រង់ដកឃ្លា ដោយប្រាប់សិស្សថា កាលណាឃើញដកឃ្លា គេត្រូវផ្អាកបន្តិច ទើបបន្តអានតទៅទៀត ។ កាលណាឃើញសញ្ញាខណ្ឌ "។"ត្រូវដាក់សំឡេង ពីព្រោះវាបញ្ចប់ល្បះនីមួយៗ ។ កាលណាឃើញសញ្ញាសួរ "?" ត្រូវលើកសំឡេងជាសំណួរ... ។
- គ្រូឱ្យសិស្សហាត់អានជាក្រុម តាំងពីដើមរហូតដល់ចប់ ។ គ្រូតាមដានកែលម្អ ។

## ៦.១៣ លំនាំបង្រៀនចម្រៀង (បទសារិកាកែវអើយ)

- គ្រូរំឭកសិស្សពីអ្វី ដែលហៅថាចម្រៀង រួចសួរសិស្ស ៖
  - តើប្អូនៗ ដែលឮគេច្រៀងចម្រៀង ឬទេ ?
  - តើប្អូនៗ ធ្លាប់ច្រៀងខ្លួនឯង ឬទេ ?
  - តើមានប្អូនណាខ្លះ ចេះច្រៀង ?
- គ្រូប្រាប់សិស្សថា យើងនឹងរៀនច្រៀងបទសារិកាកែវអើយឥឡូវនេះ
- គ្រូសរសេរអត្ថបទចម្រៀងខាងក្រោមដាក់លើក្ដារខៀន ៖

**បទសារិកាកែវអើយ**

| | |
|---|---|
| សារិកាកែវអើយ | ស៊ីអីកងៗ |
| ស៊ីផ្លែដំបង | ប្រចឹកគ្នាលេង ។ |
| ស្លាបវាចាក់ក្បាច់ | មាត់វាធ្វើភ្លេង |
| ប្រចឹកគ្នាលេង | លើមែកព្រឹក្សា ។ |

*(ដកស្រង់ចេញពីសៀវភៅកម្រងសិល្បៈសិក្សាដោយ នួន កន)*

- គ្រូអានវគ្គចម្រៀងមួយវគ្គម្តងៗ ច្បាស់ៗ ឱ្យសិស្សស្តាប់ ។ បន្ទាប់មក គ្រូចាប់ផ្តើមច្រៀងដោយធ្វើបទឱ្យសិស្សស្តាប់ រួចឱ្យសិស្សទាំងអស់គ្នាច្រៀងតាមមួយឃ្លាម្តងៗ ។
- គ្រូឱ្យសិស្សឡើងច្រៀងចម្រៀងជាក្រុម (មួយក្រុមមានគ្នា៤ ឬ៥នាក់) រហូតចប់គ្រប់គ្នា ។
- គ្រូគួរពន្យល់អត្ថន័យរបស់ចម្រៀង ឱ្យសិស្សទាំងអស់បានយល់ន័យចម្រៀងនេះផង ។

*បញ្ជាក់* ៖ចម្រៀងអាចប្រើប្រាស់បាននៅគ្រប់ពេល ដែលសិស្សលែងចាប់អារម្មណ៍នឹងការសិក្សា ។ គ្រូគប្បីនាំសិស្សច្រៀង ដើម្បីប្តូរបរិយាកាសរៀនសូត្រ និងធ្វើឱ្យសិស្សចង់រៀនតទៅទៀត ។

## ៦.១៤ លំនាំបង្រៀនមេសូត្រ

### ក. លំណែនាំ

ការបង្រៀនសូត្រមេសូត្រ គឺមានបំណងឱ្យសិស្សចេះសូត្រតាមបទនីមួយៗ បានច្បាស់លាស់ត្រឹមត្រូវ ប្រកបដោយទឹកចិត្តសប្បាយរីករាយ ហើយចេះចាំអត្ថន័យ នៃមេសូត្រនីមួយៗថែមទៀតផង ។ ខាងក្រោមនេះ ជាលំនាំបង្រៀនមេសូត្រមួយជាឧទាហរណ៍ ។

### ខ. លំនាំបង្រៀន

- គ្រូប្រើសំណួរបំផុសផ្សេងៗ ទាក់ទងនឹងការសូត្រកំណាព្យ(មេសូត្រ)ដូចជា ៖
  - តើកូនៗធ្លាប់ស្តាប់គេសូត្រកំណាព្យ ឬមេសូត្រ ឬទេ ?
  - តើនរណាជាអ្នកសូត្រមេសូត្រ ឱ្យកូនៗស្តាប់ ?
  - តើគេសូត្រពីអ្វី ?
  - តើកូនៗនៅចាំ ហើយសាកល្បងសូត្រប្រាប់គ្រូបន្តិចផងបានទេ ?
- គ្រូប្រាប់សិស្សថា ឥឡូវនេះគ្រូនឹងសូត្រឱ្យកូនស្តាប់ម្តង ។
- គ្រូសរសេរអត្ថបទមេសូត្រ ខាងក្រោមដាក់លើក្តារខៀន ៖

ម៉ែឪមានគុណ គុណមានទម្ងន់ ធ្ងន់ដូចប្រឹថពី
គ្មានអ្វីនឹងសង គុណលោកទាំងទ្វី មាសប៉ុនគីរី
ថ្លៃពុំស្មើហោង ។

- គ្រូអានអត្ថបទមេសូត្រខាងលើមួយឃ្លាម្ដងៗ ឱ្យច្បាស់ៗ ឱ្យសិស្សស្ដាប់ ។ បន្ទាប់មក គ្រូឱ្យសិស្ស ថាតាមទាំងអស់គ្នា ។
- គ្រូសូត្រដោយធ្វើបទឱ្យបានត្រឹមត្រូវ ឱ្យសិស្សស្ដាប់ឡើងវិញម្ដងទៀត ។
- គ្រូឱ្យសិស្សទាំងអស់ សូត្រធ្វើបទតាមគ្រូទាំងអស់គ្នា ។
- គ្រូឱ្យសិស្ស ២-៣នាក់ ឬសិស្សតាមក្រុមសូត្រធ្វើបទតាមគ្រូ ។
- គ្រូប្រាប់អត្ថន័យនៃកំណាព្យ ឱ្យសិស្សយល់ ។

## ៦.១៥ លំនាំបង្រៀនអក្សរផ្ចង់

### ក. លំណែនាំ

នៅថ្នាក់ទី១ សូមលោកគ្រូ អ្នកគ្រូបង្រៀនអក្សរផ្ចង់ទម្រង់អក្សរជ្រៀង ។

### ខ. លំនាំបង្រៀន

- គ្រូគូសបន្ទាត់ផ្ដេក នៅលើក្ដារខៀនតាមទម្រង់ ១/២ដូចគំរូខាងក្រោម ៖



- គ្រូណែនាំសិស្ស អំពីរបៀបគូសបន្ទាត់តាមគំរូខាងលើ ។ នៅក្នុងសៀវភៅសិស្ស មានក្រឡាបន្ទាត់ស្រេច ហើយគ្រូគ្រាន់តែនាំសិស្សគូសបន្ទាត់ទ្រេត តាមក្រឡាបន្ទាត់ក្នុងសៀវភៅសិស្សតែប៉ុណ្ណោះ ។
- គ្រូសរសេរគំរូនៅលើក្ដារខៀនយឺតៗ តាមចលនានីមួយៗ ឱ្យសិស្សសង្កេតតាម ។ ដំបូងគ្រូសរសេរអក្សរ "ក" ដោយកំណត់យកកម្ពស់ ៤/៤ ទទឹង ២/៣ បន្ទាប់មកសរសេរតួអក្សរ "ក" ដោយកំណត់យកកម្ពស់ ២/៤ ទទឹង ១/៣ ។

- គ្រូឱ្យសិស្សហាត់សរសេរអក្សរ នៅលើក្ដារឆ្នួនតាមគំរូនៅលើក្ដារខៀន ។
  - គ្រូត្រួតពិនិត្យ និងកែលម្អ ។
  - គ្រូឱ្យសិស្សហាត់សរសេរអក្សរផ្ទង់នៅក្នុងសៀវភៅរៀងៗខ្លួន និងប្រមូលមកដាក់ពិន្ទុ ។

## ៦.១៦ លំនាំបង្រៀនសរសេរតាមអានរៀបចំ

### ក. លំណែនាំ

នៅថ្នាក់ទី ១ គ្រូគប្បីបង្រៀនសរសេរតាមអានរៀបចំបែបទី ១ ដែលគេថា "សរសេរតាមអានចម្លង" ឬ "ចម្លងតាមអាន" ។ ពាក្យ កន្សោមពាក្យ និងល្បះ ដែលគ្រូយកមកឱ្យសិស្សសរសេរ ត្រូវជ្រើសរើសយកពាក្យ កន្សោមពាក្យ និងល្បះ ដែលបានរៀនរួចមកហើយ ។ ឯចំនួនពាក្យ និងកន្សោមពាក្យត្រូវមានពី ៥ ទៅ ១០យ៉ាងច្រើន និងល្បះចំនួន១ល្បះ ។

### ខ. លំនាំបង្រៀន

- គ្រូចម្លងពាក្យ កន្សោមពាក្យ ល្បះ និងអត្ថបទដាក់លើក្ដារខៀន ឬសរសេរលើក្រដាសផ្ទាំងធំ ។
- គ្រូគូសបន្ទាត់ពីក្រោមពាក្យ ដែលបម្រុងយកមកសរសេរ ហើយអានពាក្យនេះមួយម្ដងៗ ឱ្យច្បាស់ៗ ឱ្យសិស្សចង្អុលពាក្យ និងអានតាម ២-៣នាក់ ។
- គ្រូអានពាក្យទាំងនោះដោយចង្អុលផង រួចឱ្យសិស្សធ្វើអក្ខរវិញ្ញាស និងឱ្យសរសេរនៅលើក្ដារឆ្នួនទាំងអស់គ្នា ។ គ្រូដើរពិនិត្យ និងឱ្យសិស្សដែលសរសេរខុសកែឱ្យបានត្រូវឡើងវិញ ។
- គ្រូបន្តទៅពាក្យទី ២ ទី ៣ រហូតដល់ចប់ ដោយធ្វើតាមលំនាំបង្រៀនពាក្យទី១ដែរ ។
- គ្រូលាក់ពាក្យ កន្សោមពាក្យ ល្បះ និងអត្ថបទ ដែលត្រូវសរសេរតាមអាន រួចហៅឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅ ។
- គ្រូហៅ ឬអានពាក្យ កន្សោមពាក្យ និងល្បះឡើងវិញ ឱ្យសិស្សផ្ទៀង ។ ទុកពេលសមល្មមឱ្យសិស្សកែ និងបំពេញបន្ថែម ។
- គ្រូប្រមូលកិច្ចការសិស្ស កែដាក់ពិន្ទុ ។
- គ្រូឱ្យសិស្សកែកំហុសពាក្យផ្ទាល់ខ្លួន ដោយឱ្យសិស្សឆូតពីលើពាក្យខុស ហើយសរសេរពាក្យត្រូវពីលើពាក្យនោះ ។ បើសិស្សណាសរសេរខុសច្រើន គប្បីឱ្យសិស្សនោះ ចម្លងពាក្យទាំងនោះឡើងវិញ ។

## ៦.១៧ លំនាំបង្រៀនសរសេរតាមអានចម្លង

- គ្រូសរសេរពាក្យមួយចំនួន នៅលើក្ដារខៀន
- គ្រូអានពាក្យមួយម្ដងៗ ឱ្យច្បាស់ៗ ហើយឱ្យសិស្ស ២-៣នាក់ឡើងចង្អុលពាក្យនីមួយៗ អានតាម
- គ្រូចង្អុលពាក្យទី១និងអានម្ដងទៀត
- គ្រូឱ្យសិស្សធ្វើអក្ខរាវិញ្ញាសពាក្យនោះ រួចឱ្យសិស្សសរសេរនៅលើក្ដារឆ្នួនទាំងអស់គ្នា
- គ្រូត្រួតពិនិត្យ និងឱ្យសិស្សដែលសរសេរខុស កែឱ្យត្រូវឡើងវិញ
- គ្រូចង្អុលពាក្យទី ២ ទី ៣...រហូតគ្រប់ពាក្យ ហើយធ្វើតាមលំនាំបង្រៀនពាក្យទី ១ដែរ
- គ្រូហៅពាក្យឆ្លាស់គ្នា ឱ្យសិស្សសរសេរដាក់ក្នុងសៀវភៅ
- គ្រូហៅពាក្យឡើងវិញឱ្យសិស្សផ្ទៀង រួចទុកពេលឱ្យសិស្សកែ និងបំពេញបន្ថែម
- គ្រូប្រមូលសៀវភៅសិស្ស និងកែដាក់ពិន្ទុ
- គ្រូឱ្យសិស្សកែកំហុសដោយខ្លួនឯងផ្ទាល់ ដោយឱ្យសិស្សឆូតពីលើពាក្យខុស ហើយសរសេរពាក្យត្រូវពីខាងលើពាក្យនោះ
- បើសិស្សណាសរសេរខុសច្រើនលើសពី ៥ពាក្យ គប្បីឱ្យសិស្សនោះចម្លងពាក្យទាំងអស់ឡើងវិញ ។

## ៦.១៨ លំនាំបង្រៀនសរសេរតាមអានត្រួតពិនិត្យ

- ដំបូង គ្រូអានពាក្យ កន្សោមពាក្យ និងល្បះ ដែលតម្រូវឱ្យសិស្សសរសេរ ឱ្យសិស្សទាំងអស់ស្ដាប់ដោយអានឱ្យឮ និងច្បាស់ៗ
- គ្រូអាន(ហៅ)ពាក្យ កន្សោមពាក្យ ឬ ឃ្លាខ្លីៗ បីដងឱ្យសិស្សសរសេរតាមមួយម្ដងៗ រហូតដល់ចប់ ។ គ្រូអាចឱ្យសិស្ស ២នាក់ ជួយថាតាម បន្ទាប់ពីគ្រូអានចប់ ដោយឱ្យសិស្សម្នាក់ថាតាមមុននឹងខ្លួនសរសេរ ហើយម្នាក់ទៀតថាតាមក្រោយពីខ្លួនសរសេររួច ។
- ក្រោយសិស្សសរសេរតាមអានចប់ គ្រូត្រូវអានម្ដងទៀតឱ្យឮ និងច្បាស់ៗឡើងវិញ ដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់និងកែតម្រូវពាក្យ កន្សោមពាក្យ និងល្បះ ដែលគេសរសេររំលង ឬខុស
- គ្រូប្រមូលកិច្ចការសិស្ស មកកែដាក់ពិន្ទុ ។

*ចំណាំ ៖* ចំពោះការសរសេរតាមអានត្រួតពិនិត្យ លោកគ្រូ អ្នកគ្រូអាចអនុវត្តទៅតាមលទ្ធភាពដែលអាចធ្វើបាន ។

# មេរៀនទី ១ រៀនគូសបន្ទាត់ និងខ្សែកោង



*រយៈពេល ០២ ម៉ោងសិក្សា*

មេរៀនទី ២

# ចម្រៀងស្រះ

(លំនាំបទសត្វទីទុយ)



ស្រៈអ ស្រៈអា ស្រៈអិ ស្រៈអី

ពីរបូកនឹងបីឱណាយើងលៃបានប្រាំ

ស្រៈអុ ស្រៈអូ ស្រៈអួ គួរចាំ

ប្រាំបូកនឹងប្រាំឱណាយើងចាំគឺដប់ ។

មេរៀនទី
៣

# ស្រៈនិស្ស័យ



# ចម្រៀងអក្ខរក្រម ៤ វគ្គ

(លំនាំបទតាចាស់ចង់បានប្រពន្ធក្មេង)

ក ខ យើងត្រូវខិតខំ | គ គិតរៀបចំទៅសាលារៀន
ឃ ឃា ស្តាប់គ្រូបង្រៀន | ង ងា កុំអៀន ក ខ គ ឃ ង ។

(បន្ទរ ៖ ក ខ គ ឃ ង)

ច ចា រាបសារមទម | ឆ ឆី សមរម្យ ជ ជួបសំពះ
ឈ ឈប់ធ្វើអ្វីផ្ដេសផ្ដាស | ញញឹមកុំខ្មាស ច ឆ ជ ឈ ញ ។

(បន្ទរ ៖ ច ឆ ជ ឈ ញ)

ដ ឋ ឌ ឍ និងណ | ពុកម៉ែត្រេកអរឃើញកូនទៅរៀន
ត តា តាមដំបូន្មាន | សង្វាតស្វូត្ររៀន ត ថ ទ ធ ន ។

(បន្ទរ ៖ ត ថ ទ ធ ន)

ប ផ ព ភ និងម | ស្រឡាញ់រាប់រកមិត្តភក្ដិគ្រប់គ្នា
យ រ ល វ សាមគ្គា | ស ហ ឡ អ ជាសាមសិបបីតួ ។

(បន្ទរ ៖ យ រ ល វ ស ហ ឡ អ)

បញ្ជាក់ ៖ កន្លែងបន្ទរត្រូវឱ្យសិស្សស្រែកឮៗ ហើយឱ្យច្បាស់ៗ ។

មេរៀនទី
៤

# ព្យញ្ជនៈ ៣៣ តួ

| | | | | |
|---|---|---|---|---|
| ក | ខ | គ | ឃ | ង |
| ច | ឆ | ជ | ឈ | ញ |
| ដ | ឋ | ឌ | ឍ | ណ |
| ត | ថ | ទ | ធ | ន |
| ប | ផ | ព | ភ | ម |
| យ | រ | ល | វ | ស |
| ហ | ឡ | អ | | |

# មេរៀនទី ៥ ក




ក កា កិ កី កឹ កឺ កុ កូ កួ កើ កឿ កៀ កេ កែ

កៃ កោ កៅ កុំ កំ កាំ កះ កុះ កេះ កោះ

## កា កី កាំ កេះ កោះ កួ(រ)

## កកោះ កក(រ) កកូ(រ) កកេ(រ) កុះក(រ)

## កកែកក(រ)

## កុំកេះកៃ ។



កោ(រ)



កកេ(រ)

# មេរៀនទី ៦ ខ




ខ ខា ខិ ខី ខឹ ខឺ ខុ ខូ ខួ ខើ ខឿ ខៀ ខេ ខែ

ខៃ ខោ ខៅ ខុំ ខំ ខាំ ខះ ខុះ ខេះ ខោះ

## ខែ ខោ ខំ ខាំ ខួ(រ)

## ខះក កែខៃ

## កៅខះក ។



ខែ



ខោ

# មេរៀនទី ៧ ច



ច ចា ចិ ចី ចឹ ចឺ ចុ ចូ ចួ ចើ ចឿ ចៀ ចេ ចែ

ចៃ ចោ ចៅ ចុំ ចំ ចាំ ចះ ចុះ ចេះ ចោះ

## ចា(រ) ចៃ ចោ(រ) ចៅ ចាំ ចុះ ចេះ ចោះ

## ច(រ)ចា

## ចៃខាំចៅកែ ។



ចា(រ)



ចុះ

មេរៀនទី ៨

# ឆ



ឆ ឆា ឆិ ឆី ឆឹ ឆឺ ឆុ ឆូ ឆួ ឆើ ឆឿ ឆៀ ឆេ ឆែ
ឆៃ ឆោ ឆៅ ឆុំ ឆំ ឆាំ ឆះ ឆុះ ឆេះ ឆោះ

ឆា ឆី ឆៅ ឆេះ

ឆាឆៅ ឆេះខោ

ខោចៅកែឆេះ ។

ចែឆាំចេះឆា ។



ឆា



ឆេះ

# រៀនសាឡើងវិញ

## ក ខ ច ឆ



កា



កី



ខែ



ចុះ



ឆា



ឆេះ

កា កី ខែ ខូ(រ) ចៃ ចុះ ឆៅ ឆេះ

ខះក កកេ(រ) ច(រ)ចា

កុំឆាឆៅចៅកែ ។

ចៅឆាំខំខាកកេរ ។

*លំហាត់*

ចូរសរសេរអក្សរផ្ដប់អំពីព្យញ្ជនៈ “ក” ។

# មេរៀនទី ៩ ដ



ដ ដា ឌិ ឌី ឌឹ ឌឺ ដុ ដូ ដួ ដើ ដឿ ដៀ ដេ ដែ

ដៃ ដោ ដៅ ដុំ ដំ ដាំ ដះ ដុះ ដេះ ដោះ

ឌី ដៃ ដុំ ដំ ដាំ ដុះ ដូ(រ) ដើ(រ) ដេ(រ)

កដៃ ដាំដុះ ដុំឌី

ដោះដូ(រ) ដេ(រ)ខោ

ដាដេ(រ)ខោ ។

ចៅកែចេះដាំដុះ ។



ដាំ



ដើ(រ)



ដេ(រ)

មេរៀនទី ១០

# ឋ ឋ

ឋ ឋា ឋិ ឋី ឋឹ ឋឺ ឋុ ឋូ ឋួ ឋើ ឋឿ ឋៀ ឋេ

ឋែ ឋៃ ឋោ ឋៅ ឋុំ ឋំ ឋាំ ឋះ ឋុះ ឋេះ ឋោះ

ឋានីយ

ទៅឋានីយ(រ)ទេះ ។



ឋានីយ

# មេរៀនទី ១១ ណ




ណ ណា ណិ ណី ណឹ ណឺ ណុ ណូ ណួ ណើ ណឿ ណៀ ណេ

ណែ ណៃ ណោ ណៅ ណុំ ណំ ណាំ ណះ ណុះ ណេះ ណោះ

**ចំណី ចំណាំ ចំណុះ**

**ចំណោះ ដំណើ(រ)**

**កុំឆីចំណីឆៅ ។**

**ចៅណូចេះដាំដំណាំ ។**



ចំណី

# រៀនសារឡើងវិញ
# ដ ឋ ណ

ចំណោះ ចំណាំ ដំណើ(រ) កដៃ ដុំដី ដំណាំ

ចំណីឆៅ

កុំដោះដូ(រ)ដី ។

ចៅឋេខំដាំដំណាំ ។

*លំហាត់*

១. ចូរគូសភ្ជាប់រូបឱ្យត្រូវនឹងពាក្យខាងក្រោម ៖





ដំ ដេ(រ) ខោ

២. ចូរសរសេរអក្សរផ្សំអំពីព្យញ្ជនៈ “ដ” ។

# មេរៀនទី ១២ ត ថ

ត តា តិ តី តឹ តឺ តុ តូ តួ តើ តឿ តៀ ថេ ថែ

ថៃ ថោ ថៅ ថុំ ថំ ថាំ ថះ ថុះ ថេះ ថោះ

**តា តោ តៅ ថៃ ថូ ថេ(រ)**

**តាខេ ដើ(រ)តួ តេះតះ**

**ថៅតូដើ(រ)តេះតះ ។**

**តាថេចាំថៅតូចុះដី ។**



តៅ



តាខេ



ថូ



តោ

# មេរៀនទី ១៣ ប ផ





ប បា បិ បី បឹ បឺ បុ បូ បួ បើ បឿ បៀ ផេ ផែ

ផៃ ផោ ផៅ ផុំ ផំ ផាំ ផះ ផុះ ផេះ ផោះ

## បា បី បៅ បេះ ផែ ផេះ

## ដំបែ ដំបៅ បប(រ) កាផា

## ចៅបូបៅដោះ ។

## បូផាដាំបប(រ) ។



កាផា



ផែ



ដាំបប(រ) ។



ចៅបូបៅដោះ ។

# រៀនសាឡើងវិញ

## ត ថ ប ផ

តា តៅ ថែ ថេ(រ) ថោះ ផែ បី

បៅ បេះ ផេះ

តេះតះ ថៅកែ ដំបែ បំបៅ កាផា

ថៅកែថែថូ ។ កុំថាំតែថា ។

ថៅបួដើ(រ)តេះតះ ។

*លំហាត់*

១. ចូរបំពេញតួព្យញ្ជនៈជាមួយស្រៈឱ្យត្រូវនឹងរូប ខាងក្រោម ៖



េ□ា



□ូ

២. ចូរសរសេរតាមអានចម្លងនូវពាក្យចំនួនប្រាំ ។

# មេរៀនទី ១៤ ស ហ

ស សា សិ សី សឹ សឺ សុ សូ សួ សើ សឿ សៀ ហេ ហែ ហៃ
ហោ ហៅ ហុំ ហំ ហាំ ហះ ហុះ ហេះ ហោះ

សី សោ សេះ សួ(រ) ហូ(រ) ហើ(រ) ហោះ

សស(រ) ស(រ)សេ(រ) ហូ(រ)ហែ

សំណួ(រ) ស(រ)សើ(រ)

ចៅហែខំស(រ)សេ(រ) ។

តាសំស(រ)សើ(រ)សុខា ។



សេះ



ហើ(រ)



សី



ហោះ

# មេរៀនទី ១៥ ឡ ឡ អ អ





ឡ ឡា ឡិ ឡី ឡឹ ឡឺ ឡុ ឡូ ឡួ ឡើ ឡឿ ឡៀ អេ អែ អៃ
អោ អៅ អុំ អំ អាំ អះ អុះ អេះ អោះ

ឡូ អុំ អូ(រ)

កីឡា សំឡី ឡេះឡោះ

កៅអី អំបោះ អាហា(រ)

ចៅអាំដើ(រ)ឡេះឡោះ ។

សុខាកា(រ)អំបោះ ។



ឡូ



អា(រ)



កីឡា



អំបោះ



កៅអី

# រៀនសាឡើងវិញ

## ក ខ ច ឆ ជ ឋ ណ ត ថ

## ប ផ ស ហ ឡ អ

តា ណា កី ឆី តុ ថូ បួ តើ បើ តៀ ខែ ផែ ដៃ

ខោ សោ ហៅ បៅ ខំ ដំ ដាំ ខាំ បះ សះ ចុះ

ឆេះ សេះ ដោះ បោះ ហោះ

បែ(រ) ដេ(រ) សូ(រ) សួ(រ) ហូ(រ) អូ(រ) ដើ(រ)

ហើ(រ) អំបោះ ដំបៅ ហូ(រ)ហែ ស(រ)សេ(រ)

សំណួ(រ) ឡេះឡោះ ចំហ អាហា(រ) កៅអី

ចៅកែអាំឡូឡា។ ខោតាណៃឆេះ។ សំដើ(រ)ចុះផែ។

*លំហាត់*

១. ចូរសរសេរពាក្យឱ្យត្រូវនឹងរូបខាងក្រោម ៖






.......... .......... .......... ..........

២. ចូរសរសេរអក្សរផ្គុំអំពីព្យញ្ជនៈ "ហ" ។

មេរៀនទី
១៦



គ គា គិ គី គឹ គឺ គុ គូ គួ គើ គឿ គៀ គេ គែ

គៃ គោ គៅ គុំ គំ គាំ គះ គុះ គេះ គោះ

## គេ គែ គោ គុំ គោះ គ(រ) គូ(រ) គួ(រ)

## គោបា សាគ(រ) សាគូ អគា(រ) គគី(រ)

## ចៅគាគូ(រ)គោ ។

## តាគីបេះគ ។



គោបា



អគា(រ)

មេរៀនទី
១៧

# ឃ ឃ

ឃ ឃា ឃិ ឃី ឃឹ ឃឺ ឃុ ឃូ ឃួ ឃើ ឃឿ ឃៀ ឃេ ឃែ ឃៃ

ឃោ ឃៅ ឃុំ ឃំ ឃាំ ឃះ ឃុះ ឃេះ ឃោះ

## ឃូ(រ)ៗ ឃោ(រ)ឃៅ គឃៀ(រ)

## គេឃុំចោ(រ) ។

## តាឃីដើ(រ)សំដៅសាលាឃុំគី(រ) ។



ឃូ(រ)ៗ



សាលាឃុំ

មេរៀនទី
១៨

# ង



ង ងា ងិ ងី ងឹ ងឺ ងុ ងូ ងួ ងើ ងឿ ងៀ ងេ ងែ
ងៃ ងោ ងៅ ងុំ ងំ ងាំ ងះ ងុះ ងេះ ងោះ

ងា(រ) ងឿ ងំ

កា(រ)ងា(រ) ងីងើ ដំបៅងា

ចៅងឹសះដំបៅងា ។

សុខាចេះង(រ) ។



ងឿ



សុខាចេះង(រ) ។

មេរៀនទី ១៩

# ជ




ជ ជា ជិ ជី ជឹ ជឺ ជុ ជូ ជួ ជើ ជឿ ជៀ ជេ ជែ

ជៃ ជោ ជៅ ជុំ ជំ ជាំ ជះ ជុះ ជេះ ជោះ

## ជី(រ) ជូ(រ) ជួ(រ) ជឿ ជេ(រ) ជាំ ជោ(រ)

## ជីតា ជំងឺ បូជា

## កុំជឿគេ ។

## តាតែជាំជី(រ)ជាជួ(រ) ។



ជី(រ)



ជំងឺ

មេរៀនទី
២០

# ឈ ឈ

ឈ ឈា ឈិ ឈី ឈឹ ឈឺ ឈុ ឈូ ឈួ ឈើ ឈឿ ឈៀ ឈេ
ឈែ ឈៃ ឈោ ឈៅ ឈុំ ឈំ ឈាំ ឈះ ឈុះ ឈេះ ឈោះ

ឈ(រ) ឈឺ ឈើ

អា(រ)ឈើ ឈឺដៃ ឈូន(រ)

បូណាឈ(រ) ។

គេដើ(រ)ឈូន(រ) ។ តាឈុំអា(រ)ឈើ ។



បូណាឈ(រ) ។



តាឈុំអា(រ)ឈើ ។

មេរៀនទី
២១

# ញ



ញ ញា ញិ ញី ញឹ ញឺ ញុ ញូ ញួ ញើ ញឿ ញៀ ញេ ញែ ញៃ

ញោ ញៅ ញុំ ញំ ញាំ ញះ ញុះ ញេះ ញោះ

## ញី ញាំ ញុះ ញោះ

## ញញួ(រ) គោញី

## កុំញុះគេ ។

## ថៅកែគូ(រ)គោញី ។



ញញួ(រ)



ថៅកែគូ(រ)គោញី ។

# រៀនសាឡើងវិញ

# គ ឃ ង ជ ឈ ញ

គេ ឃុំ ឈើ ញាំ

គូ(រ) ងា(រ) ជេ(រ) ជោ(រ) ជួ(រ) ឈ(រ)

គគី(រ) គោញី ឃោ(រ)ឃៅ ងីងើ ញញួ(រ)

ដំបៅងា

សំចេះគូ(រ)គោញី ។

ចៅជាឈ(រ)ងីងើ ។

*លំហាត់*

១. ចូរសរសេរពាក្យឱ្យត្រូវនឹងរូបខាងក្រោម ៖



...............



...............

២. ចូរសរសេរអក្សរផ្សំអំពីព្យញ្ជនៈ "ឈ" ។

# មេរៀនទី ២២ ឡ

ឡ ឡា ឡិ ឡី ឡឹ ឡឺ ឡុ ឡូ ឡួ ឡើ ឡឿ ឡៀ ឡេ ឡែ

ឡៃ ឡោ ឡៅ ឡុំ ឡំ ឡាំ ឡះ ឡុះ ឡេះ ឡោះ

ឡឺ

ចៅឡឿចេះដើ(រ) ។

ឡីណាដាំដី(រ) ។

តាឡុំឈ(រ)ចាំចៅ ។



តាឡុំឈ(រ)ចាំចៅ ។



ចៅឡឿចេះដើ(រ) ។



ឡីណាដាំដី(រ) ។

មេរៀនទី
២៣

# ឈ



ឈ ឈា ឈិ ឈី ឈឹ ឈឺ ឈុ ឈូ ឈួ ឈើ ឈឿ ឈៀ ឈេ ឈែ ឈៃ

ឈោ ឈៅ ឈុំ ឈំ ឈាំ ឈះ ឈុះ ឈេះ ឈោះ

## ឈាមរា

## ចៅឈីចាំតាឌុំ ។



ឈាមរា

# មេរៀនទី ២៤

# ទ  ធ 

ទ ទា ទិ ទី ទឹ ទឺ ទុ ទូ ទួ ទើ ទឿ ទៀ ធេ ធែ

ធៃ ធោ ធៅ ធុំ ធំ ធាំ ធះ ធុះ ធេះ ធោះ

ទា ទី ទូ ធា(រ) ធុំ ទៅ ទុំ ធូ(រ) ទះ ទើ(រ)

ទទា ទីទៃ សាធុ ទូទៅ

ទទេ ទទូ(រ) ដទៃ សាទ(រ)

ខោសុធាធូ(រ) ។

ទទាហើ(រ)ទៅទីទៃ ។



ខោសុធាធូរ ។



ទូ



ទុំ



ទទា

# រៀនសាឡើងវិញ

## ឌ ឍ ទ ធ

ឌី ឌឺ ឌុំ ទូ ទេ ទៅ ទុំ ធំ ទើ(រ) ទេ(រ) ទោ(រ)

ទីទៃ ទទូ(រ)

តាឌុំទះដៃ ។

ទទាហើ(រ)ទៅទីទៃ ។

*លំហាត់*

១. ចូរសរសេរពាក្យឱ្យត្រូវនឹងរូបខាងក្រោម ៖







.............. .............. ..............

២. ចូរសរសេរតាមអានចម្លងពាក្យចំនួនប្រាំនិងមួយ

ល្បះ ។

# មេរៀនទី ២៥ ន  ព 

ន នា និ នី នឹ នឺ នុ នូ នួ នើ នឿ នៀ ពេ ពែ

ពៃ ពោ ពៅ ពុំ ពំ ពាំ ពះ ពុះ ពេះ ពោះ

នៅ នំ នោះ ពាំ ពុះ ពោះ ពៅ

ផានា ទំនេ(រ) គំនូ(រ)

ពូថៅ ពពែ សំពៅ សំពះ

សុខាចេះសំពះ ។

នាឡិកានេះធំ ។



សំពះ



សំពៅ



គូរគំនូរ



នាឡិកា



ពូថៅ

# មេរៀនទី ២៦ ភ ភ ម ម

ភ ភា ភិ ភី ភឹ ភឺ ភុ ភូ ភួ ភើ ភឿ ភៀ មេ មែ មៃ

មោ មៅ មុំ មំ មាំ មះ មុះ មេះ មោះ

## ភ(រ) ភេ មា មេ មូ(រ) មាំ

## ភាសា សំភោ(រ) មមើ

## មេអំបៅ



តាភុំទះសំភោ(រ) ។

## បងសុភីចេះបីភាសា ។

## តាភុទះសំភោ(រ) ។

## មេអំបៅទំលើពពែញ្ញី ។



ភេ



មេអំបៅ

# រៀនសាឡើងវិញ

## ន ព ភ ម

នៅ នំ នោះ ពៅ ពាំ ភេ ភ(រ) មុំ

មមី មមៃ ភូមា កា(រ)ពា(រ) ពុះពា(រ) ភាសា

មេអំបៅ មមីមមើ

កុំភ(រ)គេ ។ សុខាចេះសំពះ ។

តាភុំទះសំភោ(រ) ។ មេអំបៅទំលើពពែញី ។

*លំហាត់*

១. ចូរជ្រើសរើសពាក្យឱ្យត្រូវនឹងរូបខាងក្រោម ៖

១. គោ

២. ភេ

៣. ពពែ



១. មេទា

២. មេឃុំ

៣. មេអំបៅ



២. ចូរសរសេរតាមអានចម្លងពាក្យចំនួនប្រាំនិងមួយល្បះ ។

# មេរៀនទី ២៧ យ យ រ រ

យ យា យិ យី យឹ យឺ យុ យូ យួ យើ យឿ យៀ

រេ រែ រៃ រោ រៅ រុំ រំ រាំ រះ រុះ រេះ រោះ

យួ(រ) យំ រៃ រាំ

យីកេ រទេះ រងា យាគូ គីរី រំពេ

យោធា រណារ

ចៅកែយំ ។

ពូពៅប(រ)រទេះគោ ។



ពូពៅប(រ)រទេះគោ ។

យោធាកា(រ)ពា(រ)ដីកោះ ។



យោធា



យួរ



យំ



រាំ

មេរៀនទី ២៨

# ល ល វ វ

ល លា លិ លី លឹ លឺ លុ លូ លួ លើ លឿ លៀ

វេ វែ វៃ វោ វៅ វុំ វំ វាំ វះ វុះ វេះ វោះ

## លី លូ លើ លៃ លះ វា វៃ

## រលំ លំហែ លំនៅ វិថី វេលា នាវា ទីលំនៅ

## នារីរវៃអំបោះ ។

## ពូឃុំលីឈើ ។

## ពូរីចុះពីលើនាវា ។



នារីរវៃអំបោះ ។



លូ



នាវា



លីឈើ

# រៀនសាឡើងវិញ (ព្យញ្ជនៈពួក អ៊ី)

## គ ឃ ង ជ ឈ ញ ឌ ឍ

## ទ ធ ន ព ភ ម យ រ ល វ

គគីរ ឃោរឃៅ រងា ញញួរ ទទូរ ទំនេរ រំពេ

វេលា យោធា មមី មមើ

ឱណាចេះដាំជី(រ) ។ មេអំបៅទំលើពពេញ ។

មេឃុំឈ(រ)រេរានៅសាលាឃុំ ។

*លំហាត់*

១. ចូរគូសភ្ជាប់រូបឱ្យត្រូវនឹងពាក្យខាងក្រោម ៖







រំពេ ញញួរ ទទា

២. ចូរសរសេរអក្សរផ្គង់អំពីព្យញ្ជនៈ "យ" ។

# រៀនសាឡើងវិញ
# ព្យញ្ជនៈពួក អ និងពួក អ៊

កា ខោ គោ ឃុំ ងំ ចៅ ឆេះ ជាំ ឈើ ញី ដុំ ឋា

ឌុំ ឍី ណើ តោ ថូ ទា ធំ នំ បី បោះ ផេះ ពោះ

ភេ មី យំ រៃ លី វះ សី ហា ឡូ អេះ

កៅអី កា(រ)ងា(រ) គោញី សីហា ដំបៅងា

ពពែញី

មេអំបៅហើ(រ)។ តាភុំបីចៅ។ នារីឈើពោះ។

*លំហាត់*

១. ចូរសរសេរបំពេញព្យញ្ជនៈក្នុងចន្លោះឱ្យត្រូវតាមលំដាប់។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ក | ខ | ... | ឃ | ង | ... | ឆ | ជ | ... | ញ |
| ដ | ... | ឌ | ឍ | ... | ត | ថ | ... | ធ | ន |
| ... | ផ | ... | ភ | ម | យ | ... | ល | ... | |
| ស | ហ | ... | អ។ | | | | | | |

២. ចូរសរសេរអក្សរផ្សំអំពីព្យញ្ជនៈ "ទ"។

# មេរៀនទី ២៩ បទចម្រៀង "សារិកាកែវអើយ"



សារិកាកែវអើយ ស៊ីអីកងៗ
ស៊ីផ្លែដំបង ប្រចឹកគ្នាលេង ។
ស្លាបវាចាក់ក្បាច់ មាត់វាធ្មើភ្លេង
ប្រចឹកគ្នាលេង លើមែកព្រឹក្សា ។

មេរៀនទី
# ៣០ ង៉

ង៉ ង៉ា ង៉ិ ង៉ី ង៉ឹ ង៉ឺ ង៉ុ ង៉ូ ងួ ង៉ើ ងឿ ងៀ ង៉េ ង៉ែ

ង៉ៃ ង៉ោ ង៉ៅ ង៉ុំ ង៉ំ ង៉ាំ ង៉ះ ង៉ុះ ង៉េះ ង៉ោះ

## ង៉ែង៉រ

## ចៅង៉ោចេះយំង៉ាៗ ។

## ចៅង៉ូចេះដើរតេះតះ ។



ចៅង៉ូចេះដើរតេះតះ ។

*ចំណាំ*

- មូសិកទន្ត ឬ ធ្មេញកណ្ដុរ (៉) ជាវណ្ណយុត្តសម្រាប់ប្រើសម្លាប់បំបែរ សំឡេងព្យញ្ជនៈពួក អ៊ ឱ្យទៅជាពួក អ ។
- ចំពោះស្រៈ ួ ឿ ៀ មិនចាំបាច់ប្រើសញ្ញាមូសិកទន្ត(៉) ទេ ព្រោះ ការប្រើសញ្ញានេះក៏សូរមិនដូរដែរ ។

មេរៀនទី
៣១

# ញ៉

ញ៉ ញ៉ា ញ៉ិ ញ៉ី ញ៉ឹ ញ៉ឺ ញ៉ុ ញ៉ូ ញ៉ួ ញ៉ើ ញ៉ឿ ញ៉ៀ ញ៉េ ញ៉ែ
ញ៉ៃ ញ៉ោ ញ៉ៅ ញ៉ុំ ញ៉ំ ញ៉ាំ ញ៉ះ ញ៉ុះ ញ៉េះ ញ៉ោះ

## ញ៉ែ ញ៉ាំ

## ញ៉េះញ៉ោះ ញ៉ាំញ៉ី

## នារីញ៉ាំមី ។

## សុភីញ៉េះញ៉ោះបូណា ។



នារីញ៉ាំមី ។

# មេរៀនទី ៣២ ប៉

ប៉ ប៉ា ប៉ិ ប៉ី ប៉ឹ ប៉ឺ ប៉ុ ប៉ូ ប៉ួ ប៉ើ ប៉ឿ ប៉ៀ ប៉េ ប៉ែ

ប៉ៃ ប៉ោ ប៉ៅ ប៉ុំ ប៉ំ ប៉ាំ ប៉ះ ប៉ុះ ប៉េះ ប៉ោះ

## ប៉ី ប៉ះ ចាប៉ី ប៉ីអ ហោប៉ៅ

## តាប៉ូកេះចាប៉ី ។



ប៉ីអ



តាប៉ូកេះចាប៉ី ។

មេរៀនទី
៣៣

# ម៉

ម៉ ម៉ា ម៉ិ ម៉ី ម៉ឹ ម៉ឺ ម៉ុ ម៉ូ មួ ម៉ើ មឿ មៀ ម៉េ
ម៉ែ ម៉ៃ ម៉ោ ម៉ៅ ម៉ុំ ម៉ំ ម៉ាំ ម៉ះ ម៉ុះ ម៉េះ ម៉ោះ

ម៉ែ ម៉ាំ ម៉ៅ

មួម៉ៅ រម៉េះរម៉ោះ

ម៉ែបូណាប៉ះហោប៉ៅខោ ។



ម៉ែបូណាប៉ះហោប៉ៅខោ ។

មេរៀនទី
៣៤

# យ៉

យ៉ យ៉ា យ៉ិ យ៉ី យ៉ឹ យ៉ឺ យ៉ុ យ៉ូ យ៉ួ យ៉ើ យ៉ឿ យ៉ៀ យ៉េ
យ៉ែ យ៉ៃ យ៉ោ យ៉ៅ យ៉ុំ យ៉ំ យ៉ាំ យ៉ះ យ៉ុះ យ៉េះ យ៉ោះ

## រយ៉ា អាយ៉ៃ ឆៃយ៉ាំ
## នារីរាំឆៃយ៉ាំ ។



នារីរាំឆៃយ៉ាំ ។

# មេរៀនទី ៣៥ រ៉

រ៉ រ៉ា រ៉ិ រ៉ី រ៉ឹ រ៉ឺ រ៉ុ រ៉ូ រួ រ៉ើ រឿ រៀ រ៉េ រ៉ែ រ៉ៃ

រ៉ោ រ៉ៅ រ៉ុំ រ៉ំ រ៉ាំ រ៉ះ រ៉ុះ រ៉េះ រ៉ោះ

**រ៉ាំរ៉ៃ រណារ៉**

**តាឈុំឈឺរ៉ាំរ៉ៃ ។**



រណារ៉



តាឈុំឈឺរ៉ាំរ៉ៃ ។

# មេរៀនទី ៣៦ វ៊

វ៊ វ៊ា វ៊ិ វ៊ី វ៊ឹ វ៊ឺ វ៊ុ វ៊ូ វួ វ៊ើ វ៊ឿ វ៊ៀ វ៊េ វ៊ែ វ៊ៃ

វ៊ោ វ៊ៅ វ៊ុំ វ៊ំ វ៊ាំ វ៊ះ វ៊ុះ វ៊េះ វ៊ោះ

វ៊ៃ ចៅវ៊ា

ពូវ៊ៅវ៊ៃគោ ។

ចៅវ៊ាចេះវារ ។



ចៅវ៊ាចេះវារ ។

# រៀនសាឡើងវិញ

# ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉

ង៉ា ញ៉ាំ ប៉ី ម៉ែ ម៉ាំ យ៉ៃ រ៉ៃ រ៉ាំ វ៉េះ

ចាប៉ី រយ៉ា រម៉េះរម៉ោះ រ៉ាំរ៉ៃ តាវ៉ៅ ញ៉េះញ៉ោះ

ហោប៉ៅ

ចៅរ៉ាពូកែរាំឆៃយ៉ាំ ។

ម៉ែបូណាប៉ះហោប៉ៅខោ ។

*លំហាត់*

១. ចូរជ្រើសរើសពាក្យមកសរសេរឱ្យត្រូវនឹងរូប
ខាងឆ្វេង ។

| | |
|---|---|
|  .............. | រយ៉ា ឆៃយ៉ាំ ចាប៉ី |

២. ចូរស្រង់ពាក្យដែលប្តូរពី ( ៉ ) ទៅជា ( ុ ) ឱ្យបាន
ចំនួនបីពាក្យ ។

មេរៀនទី ៣៧

# ប៊

ប៊ ប៊ា ប៊ិ ប៊ី ប៊ឹ ប៊ឺ ប៊ុ ប៊ូ បួ ប៊ើ បឿ បៀ ប៊េ ប៊ែ
ប៊ៃ ប៊ោ ប៊ៅ ប៊ុំ ប៊ំ ប៊ាំ ប៊ះ ប៊ុះ ប៊េះ ប៊ោះ

សាប៊ូ

សាប៊ូពីរដុំ ។

បូណាដូរសាប៊ូ ។



សាប៊ូពីរដុំ ។

*ចំណាំ*

- ត្រីស័ព្ទ ( ៊ ) ជាវណ្ណយុត្តសម្រាប់ប្រើលើព្យញ្ជនៈ ៤តួគឺ ប ស ហ អ ។
- ចំពោះស្រៈ ួ ឿ ៀ មិនចាំបាច់ប្រើសញ្ញាត្រីស័ព្ទ ឬ សក់ក ( ៊ ) ទេ ព្រោះការប្រើសញ្ញានេះក៏សូរមិនដូរដែរ ។

មេរៀនទី
៣៨

# ស៊

ស ស៊ា ស៊ិ ស៊ី ស៊ឹ ស៊ឺ ស៊ុ ស៊ូ ស៊ួ ស៊ើ ស៊ឿ ស៊ៀ ស៊េ ស៊ែ ស៊ៃ
ស៊ោ ស៊ៅ ស៊ុំ ស៊ំ ស៊ាំ ស៊ះ ស៊ុះ ស៊េះ ស៊ោះ

ស៊ី ស៊ូ ស៊ាំ
ភាស៊ី តស៊ូ កៅស៊ូ
យោធាតស៊ូការពារដីកោះ ។



កៅស៊ូ



យោធាតស៊ូការពារដីកោះ ។

មេរៀនទី
៣៩

# ហ៊

ហ៊ ហ៊ា ហ៊ិ ហ៊ី ហ៊ឹ ហ៊ឺ ហ៊ុ ហ៊ូ ហ៊ួ ហ៊ើ ហ៊ឿ ហ៊ៀ ហ៊េ ហ៊ែ ហ៊ៃ
ហ៊ោ ហ៊ៅ ហ៊ុំ ហ៊ំ ហ៊ាំ ហ៊ះ ហ៊ុះ ហ៊េះ ហ៊ោះ

នំហ៊ូ

តាប៊ីពិសានំហ៊ូ ។



នំហ៊ូ


បោះពុម្ពផ្សាយ ឆ្នាំ ២០១៦PDH

មេរៀនទី ៤០

# អ៊

អ៊ អ៊ា អ៊ិ អ៊ី អ៊ឹ អ៊ឺ អ៊ុ អ៊ូ អ៊ួ អ៊ើ អ៊ឿ អ៊ៀ អ៊េ

អ៊ែ អ៊ៃ អ៊ោ អ៊ៅ អ៊ុំ អ៊ំ អ៊ាំ អ៊ះ អ៊ុះ អ៊េះ អ៊ោះ

អ៊ូ អ៊ំ

អ៊ូអរ រអ៊ូ

ទីនេះអ៊ូអរ ។

អ៊ំយ៉ាឈររអ៊ូ ។



អ៊ូអរ

# រៀនសាឡើងវិញ

# ប៊ ស៊ ហ៊ អ៊

សាប៊ូ កៅស៊ូ តៅហ៊ូ រអ៊ូ ហ៊ឺហា

ចៅប៊ឺថាទីនេះអ៊ូអរ ។

អាគីចេះស៊ីតៅហ៊ូ ។

កុមារខំតស៊ូទៅសាលា ។

*លំហាត់*

១. ចូរបំពេញស្រៈឬវណ្ណយុត្តឱ្យត្រូវនឹងរូបខាងក្រោម ៖



តៅហ៊...



...ក...សូ



ស...បូ

២. ចូរសរសេរអក្សរផ្តង់អំពីព្យញ្ជនៈ "ញ" ។

មេរៀនទី
៤១

# ម៉ែឪមានគុណ



## *មេសូត្រត្រវត់មាត់*

ម៉ែឪមានគុណ គុណមានទម្ងន់

ធ្ងន់ដូចប្រឹថពី គ្មានអ្វីនឹងសង

គុណលោកទាំងទ្វី មាសប៉ុនគីរី

ថ្លៃពុំស្មើហោង ។

# មេរៀនទី ៤២ ប្រកបនឹង ⬚ក ⬚ក់

កក ខក ចក ដក តក បក សក ឡក អក

កក់ ខក់ ចក់ ដក់ តក់ បក់ សក់ ឡក់ អក់

កាក ខាក ចាក ដាក បាក សាក

កាក់ ខាក់ ចាក់ ដាក់ បាក់ សាក់

កុក ចុក ចូក ចែក ដែក ផឹក សឹក

ចចក អំបុក បំបែក ចំណែក ដំណោក ចេកទុំ

កុកហើរ ។ នារីកក់សក់ ។

សេកចឹកចេកទុំស៊ីលើសំបុក ។



ផឹក



កុក



កក់សក់

*ចំណាំ*

សញ្ញាបន្តក់ ( ់ ) ជាវណ្ណយុត្តសម្រាប់បំបែរសូរវែងឱ្យមកជាសូរខ្លី ។

# មេរៀនទី ៤៣ ប្រកបនឹង ◌ក ◌ក់ (ត)

គក ងក ជក ភក លក វក

គក់ ងក់ ជក់ ភក់ លក់ វក់

ពាក ផាក រាក លាក

ពាក់ ផាក់ រាក់ លាក់

ជីក មួក មែក រីក វែក

លូក លើក វើក វែក

ពពក លលក ទឹករាក់ ដីភក់ វីវក់

ពុកពាក់មួកទៅជីកដីភក់ ។



មួក



ពុកពាក់មួកទៅជីកដីភក់ ។

មេរៀនទី
៤៤

# ប្រកបនឹង ⬚ង ⬚ង់

កង ចង ដង ថង បង សង

កង់ ចង់ ដង់ ថង់ បង់ សង់

កេង កែង កោង ខាង ខឹង ចុង ចែង ឆឹង ឆុង ជឹង

ដូង តឹង តោង បែង បាំង សៀង សែង សាំង អាំង

សំណាង ដំណឹង តឹងតែង

បំណង សំណង់ ចុងដូង

កុំតោងកង់មីងសុង ។

បងរិចង់សង់រោងខាងចុងបឹង ។



ដូង



អាំង



កុំតោងកង់មីងសុង ។

មេរៀនទី
៤៥

# ប្រកបនឹង □ង □ង់ (ត)

គង ជង ទង រង វង លង

គង់ ជង់ ទង់ រង់ វង់ លង់

ជាង ដើង ពាង ពែង

រឹង រូង លាង លេង វែង វាំង

ដងទង់ វាំវង់ ទំពាំង រនាំង

យើងកុំចុះលេងទឹកបឹង ។

មីងគង់លាងពាងនិងផុងទឹក ។


ពាង


ពែង

# មេរៀនទី ៤៦ ប្រកបនឹង ◌ច ◌ច់

កាច ដាច បាច សាច ប៉ាច

កាច់ ដាច់ បាច់ សាច់ ប៉ាច់

ខើច ខូច តិច តូច បោច សើច ហួច ក្តួច ហុច ចុច

បាចសាច តូចតាច ចាំបាច់ សាច់គោ ដាច់ខែ

សំណើច

ចៅម៉ាចចេះហួចនិងសើចតិចៗ ។

កុំបាចទឹកដាក់គេដូចពូកៅ ។



បាចទឹក

មេរៀនទី ៤៧

# ប្រកបនឹង ◌ច ◌ច់ (ត)

ជច ទច ញច អ៊ិច

ជច់ ទច់ ញច់ អ៊ិច់

គេច ទោច រេច រោច លិច លួច វេច វៀច ជុច

រនោច លិចលង់ សំពោច

តាអ៊ុចមុជទឹកបឹងខាងលិច ។

ពូចាក់សោការពារចោរលួច ។



ជុច

# រៀនសាឡើងវិញ

# ក ក់ ង ង់ ច ច់

កក់សក់ មុជទឹក លំចង់ កែងជើង រំលេច

ចាំបាច់ ទំពាំង ពីងពាង

យើងកុំជក់បារី ។

ពូអ៊ុងរែកចេកទៅលក់ ។

បងសំណាងបើកហាងសាំង ។

*លំហាត់*

១. ចូរសរសេរពាក្យឱ្យត្រូវនឹងរូបខាងក្រោម ៖



.............. .............. ..............

២. ចូរសរសេរតាមអានរៀបចំឱ្យបានប្រាំពាក្យ ។

មេរៀនទី
៤៨

# ប្រកបនឹង ◌ញ ◌ញ់

កញ ខញ ចញ ដញ បញ សញ

កញ់ ខញ់ ចញ់ ដញ់ បញ់ សញ់

កាញ កាញ់ ខាញ ខាញ់ ចាញ ចាញ់ញ៉ាញ ញ៉ាញ់

ដាញ ដាញ់ បាញ បាញ់ សាញ សាញ់ ម៉ាញ ម៉ាញ់

ចេញ ដេញ កុញ សុញ កំណាញ់ ចុះចាញ់

បរបាញ់ សំណាញ់ ចំណោញ

កុំបរបាញ់ ។

ពូសាញ់បង់សំណាញ់ ។



ពូសាញ់បង់សំណាញ់ ។

មេរៀនទី ៤៩

# ប្រកបនឹង ញ ញ់ (ត)

ទញ លញ ស៊ញ

ទញ់ លញ់ ស៊ញ់

ទាញ ទិញ ជួញ ទួញ រុញ រួញ រិញ ឃើញ

ជំនាញ ទំនិញ ជំនួញ ពេញលេញ បំពេញ

ពូពេញដឹកទំនិញ ។

មីងសាញ់ជំនាញខាងលក់ទំនិញ ។



រុញ

# មេរៀនទី ៥០ ប្រកបនឹង ⬚ត ⬚ត់

កត ចត ហត បត សត អត

កត់ ចត់ ហត់ បត់ សត់ អត់

កាត ខាត ចាត បាត ហាត

កាត់ ខាត់ ចាត់ បាត់ ហាត់

កើត ចិត ឆើត ដោត បឺត ផុត ម៉ត់

សៀត សួត ហុត អួត

សំប៉ែត ចំណត បាត់បង់ កំណាត់

កាំបិត កំណើត ចំណោត

កាំបិតបាក់ជាពីរកំណាត់ ។

ពូសុតអួតតាំងពីកំណើត ។



កាំបិត

មេរៀនទី
៥១

# ប្រកបនឹង □ត □ត់ (ត)

គត មត រត លត

គត់ មត់ រត់ លត់

ពត ពត់ មាត មាត់ គាត គាត់ ទាត ទាត់ ផាត ផាត់

គិត ងូត ជួត មុត ពោត លោត ទៀត

ពិត ស៊ុត អ៊ុត ធំធាត់ ងូតទឹក សំពត់

ទៀងទាត់ រំពាត់ រលាត់ ងងឹត

ពូឈឿតដុតពោត ។

បូណាងូតទឹកពាង ។



លោត



អ៊ុត



បូណាងូតទឹកពាង ។

មេរៀនទី
៥២

# ប្រកបនឹង ◌ន ◌ន់



ប៉ាន់

កន ខន បន អន ប៉ន

កន់ ខន់ បន់ អន់ ប៉ន់

កាន ខាន ថាន ឆាន ប៉ាន

កាន់ ខាន់ ថាន់ ឆាន់ ប៉ាន់

កិន កុន កើន ចិន ប៉ិន ប៉ែន

ចៀន បួន ណែន

អំណាន ចំនួន ណែនណាន់ ចេកចៀន

ពូប៉ែនប៉ិនតៀនកូនអានរឿងនិទាន ។

បងណាននិងកូនពូកែថែសួន ។



អាន



បងណាននិងកូនពូកែថែសួន ។

មេរៀនទី ៥៣

# ប្រកបនឹង ◌ន ◌ន់ (ត)

គន ទន ផន មាន ពាន ទាន រាន លាន

គន់ ទន់ ផន់ មាន់ ពាន់ ទាន់ រាន់ លាន់

គែន ជួន ជាន់ ពួន ពេន ទៀន រៀន លឿន

ជីដូន ទុរេន មេមាន់ ជើងពាន ជឿនលឿន

ពូនន់ជូនកូនទៅសាលារៀន។

មីងអ៊ុនទិញមេមាន់មីងជឿន។



ជើងពាន



ទុរេន

# រៀនសាឡើងវិញ

## ញ ញ់ ត ត់ ន ន់

សំណាញ់ ចំណោញ កាំបិត ជួ(រ)ចត់

ញញើត ទំនួញ មេមាន់ សំប៉ែត ម៉ត់ចត់ ម៉ឹងម៉ាត់

សាលារៀន ទឹកជំនន់

មីងនួនជូនកូនទៅសាលារៀន ។

ខែមុនមានទឹកជំនន់នៅបាត់ដំបង ។

*លំហាត់*

១. ចូរសរសេរពាក្យឱ្យត្រូវនឹងរូបខាងក្រោម ៖







............... ............... ...............

២. ចូរសរសេរតាមអានរៀបចំពាក្យចំនួនប្រាំនិងមួយល្បះ ។

មេរៀនទី
៥៤

# ប្រកបនឹង ⬚ប ⬚ប់

តប ដប ចប កប ឆប ប៉ប

តប់ ដប់ ចប់ កប់ ឆប់ ប៉ប់

ចាប ដាប ឆាប សាប

ចាប់ ដាប់ ឆាប់ សាប់

ចបកាប់ ដែកថែប កំណាប់

សំណាប ចំបាប់ ចំណាប់

ពូចេបលីចបទៅកាប់ដី ។

ក្ុកសាប់ចាប់ចំណី ។



ចំបាប់



ចបកាប់



ក្ុកសាប់

# មេរៀនទី ៩៥ ប្រកបនឹង ◌ប ◌ប់ (ត)

គប លប ឈប ជប ស៊ប

គប់ លប់ ឈប់ ជប់ ស៊ប់

លាប គាប រាប ជាប ងាប

លាប់ គាប់ រាប់ ជាប់ ងាប់

គួប ជួប ទាប ធូប ធៀប លុប ស៊ុប យប់

ទំនប់ រលុប រនាប រំភើប រៀបរាប់ យីហ៊ុប

បងសុខាលាបថ្នាំរបង ។

យប់មិញសុខារៀបរាប់ពីការលើកទំនប់ ។



ធូប



បងសុខាលាបថ្នាំរបង ។

មេរៀនទី
៥៦

# ប្រកបនឹង ◌ម

កម ខម ចម តម ហម សម ប៉ម ប៉ោម

តាម ចាម ដាម ហាម សាម ញ៉ាម

ចោម ចៀម មៀម ថែម បូម សូម សើម ហើម

ប៊ីបម សាមសិប សំណើម ចំអាម សំរាម

ចចកចោមខាំកូនចៀម ។

តាហាមបូមទឹកដាក់ដើមទុរេន ។



មៀម



ចៀម

មេរៀនទី
៥៧

# ប្រកបនឹង ⬚ម (ត)

គម ងម ជម ទឹម នឹម គោម រោម

រៀម មើម ឈាម យាម

ទទឹម រលឹម ទំនៀម ល្ហុងលោម

ញញឹម នំគម

ពូស៊ីមទឹមគោទៅដឹកមើមដំឡូង ។

ចៅម៉មញញឹមតាមតាល្ហុងលោម ។



ទទឹម



នំគម

មេរៀនទី
៥៨

# ប្រកបនឹង ◌យ

កយ តយ សយ ថយ ឆយ

កាយ ចាយ បាយ សាយ

កុយ កើយ សើយ ផុយ

ហុយ ហើយ សោយ

កកាយ ចំហាយ ចំហុយ

រហើយ រប៉ាត់រប៉ាយ

ពូស្ងួយកាយដី ។

ចៅកយចេះដាំបាយ ។



បាយ



ចៅកយចេះដាំបាយ ។



ពូស្ងួយកាយដី ។

មេរៀនទី ៥៩

# ប្រកបនឹង ◌យ (ត)

គយ ញយ ទយ លយ ពយ រយ ស៊យ

ងាយ ជាយ ទាយ នាយ យាយ លាយ វាយ

រាយ គួយ ងើយ នឿយ ភួយ រោយ រួយ

ញឹកញយ មួយរយ និយាយ

ទីទុយ រីករាយ នឿយណាយ

រុយរោមសំរាមរលួយ ។

យាយស៊ុយនឿយណាយមិនរីករាយទេ ។




រុយរោមសំរាមរលួយ ។



ទីទុយ

# រៀនសាឡើងវិញ

## ប ប់ ម យ

ចបកាប់ ចំណាប់ មួយរយ រីករាយ រាយមាយ

រុះរោយ រួបរួម រលីបរលោប ញញឹមញញែម

កូនមៀមទំលើដើមឈើងាប់ ។

យើងរួមការងារដោយញញឹមញញែម ។




មួយរយរៀល



មៀម

*លំហាត់*

១. ចូរសរសេរពាក្យឱ្យត្រូវនឹងរូបខាងក្រោម ៖





.................... ....................

២. ចូរសរសេរអក្សរផ្ដុំអំពីព្យញ្ជនៈ "ហ" ។

មេរៀនទី
៦០

# ប្រកបនឹង ◌ល ◌ល់

កល ដល សល វ៉ល

កល់ ដល់ សល់ វ៉ល់

ដាល បាល ហាល

ដាល់ បាល់ ហាល់

ផាល ខាល ដួល បោល

ចូល ហូល ហែល

កប៉ាល់ អំបិល ដំបូល បបែល កំសួល

ថៅបុលចោលបាល់ ។

កប៉ាល់ដឹកអំបិលទៅឃុំកោះខែល ។



ថៅបុលចោលបាល់ ។



បបែល



កប៉ាល់

# មេរៀនទី ៦១ ប្រកបនឹង ◌ល ◌ល់ (ត)

គល ជល ទល យល វល

គល់ ជល់ ទល់ យល់ វល់

វាល ពាល គាល

វាល់ ពាល់ គាល់

រិល ពិល ពុល មួល មើល យោល រៀល

ទទួល រំដួល រសៀល អំពិលអំពែក

បូណាទទួលលុយមួយរយរៀលពីរំដួល ។

ពេលរសៀលពូម៉ាល់រវល់លេងបាល់ ។



ពិល



ជល់

មេរៀនទី
៦២

# ប្រកបនឹង ◌រ

ការ ចារ ដារ ឡារ បារ អារ

ខៀរ ហោរ កែរ ចែរ ជារ រារ

កំសៀរ ឡេវអារ សៀវភៅ

សារម៉ារ អំពារនារ

តាម៉េរដេញសាដៀរ ។

ចៅកែរកំពុងញុំាសារម៉ារ ។

ពូខៀរតឿនកូនអានសៀវភៅ ។



តាម៉េរដេញសាដៀរ ។



កែវ



កំសៀវ



សារម៉ារ

មេរៀនទី
៦៣

# ប្រកបនឹង ◌ស ◌ស់

អស បស

អស់ បស់

ចាស កាស

ចាស់ កាស់

ដុស ហួស ដួស បោស កោស

កំហុស អំបោស បំបួស របួស ចៀសវាង

យើងបោសសំរាម ។

ចៅសួសហ៊ានទទួលកំហុស ។



យើងបោសសំរាម ។

# មេរៀនទី ៦៤ ប្រកបនឹង ◌ស ◌ស់ (ត)

ពស រស លស

ពស់ រស់ លស់

គាស ញាស ទាស

គាស់ ញាស់ ទាស់

មាស មាស់ វាស វាស់ វ៉ាស វ៉ាស់

លើស លៀស ទោស ញើស រើស ជួស

រនាស់ ឈើគូស ជួសជុល

ពស់វែកមានពិស ។

ពូរស់លីរនាស់ទៅរាស់ដី ។

ចៅសួសហ៊ានសុំទោសពេលមានកំហុស ។



ឈើគូស



ពូរស់លីរនាស់ទៅរាស់ដី ។



ជួសជុល

# រៀនសាឡើងវិញ

# ល ល់ រ ស ស់

គល់ឈើ បបួល ជួសជុល សៀវភៅ កំហុស

ពិល រាលដាល កំសៀវ ឈើគូស ពិសេស

អំពាវនាវ រដូវរំហើយ

រំដួលងូតទឹកដុសសាប៊ូរាល់ពេល ។

រដូវរំហើយចាស់ៗរវល់នឹងការងារ ។

*លំហាត់*

១. ចូរសរសេរពាក្យឱ្យត្រូវនឹងរូបខាងក្រោម ៖







.............. .............. ..............

២. ចូរសរសេរអក្សរផ្គុំអំពីព្យញ្ជនៈ "ឡ" ។

# មេរៀនទី ៦៥ ស្រះពេញតួ អ អា ឥ ឦ ឧ ឩ ឪ

អគារ អាកាស ឥសី ឥឡូវ ឦសាន ឧសភា

ឧទាហរណ៍ ឧទាន ឩដ្ឋ ឪពុក ឪឡឹក ឪម៉ាល់

ឪពុកដាំឪឡឹកនៅដើមខែឧសភា ។

ឥឡូវនេះជំនោរបក់មកពីទិសឦសាន ។



ឥសី



ឪឡឹក



ឪម៉ាល់

# មេរៀនទី ៦៦ ស្រះពេញតួ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ

ឫស រឭក ឯណា ឰដ៏ ឱកាស

ឱសថ ឱវាទ ឱ៉ាល់ ក្រឪ

ក្រឪឈ្លូកនៅឯណា ?

តើឯងឮគេហៅឬទេ ?

ពពករសាត់ឰដ៏អាកាស ។

គួរទុកឱកាសឱ្យសិស្សកែកិច្ចការដោយឯកឯង ។



ឱសថ



ឫស

# រៀនសាឡើងវិញស្រះពេញតួ

# អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ

# ឭ ឮ ឯ ឰ ឱ ឳ

អគារ ឥសី ឥឡូវ ឦសាន ឧសភា ឩដ្ឋ ឪឡឹក

ឫកពា រឭក ឯណា ឰដ៏ ឱកាស ឱសថ ក្រឳ

តើឯងឮគេហៅឬទេ ?

ពពករសាត់ឰដ៏អាកាស ។

ឥឡូវជំនោរបក់ពីទិសឦសាន ។

ម៉ែឪគួរទុកឱកាសដល់កូនបានរៀនជាប់លាប់ ។

*លំហាត់*

១. ចូរសរសេរស្រះពេញតួឱ្យបានប្រាំបីតួ ។

២. ចូរសរសេរអក្សរផ្គង់ស្រះពេញតួ “ឯ” ។

# មេរៀនទី ៦៧ ព្យញ្ជនៈ និងជើងព្យញ្ជនៈ

ក្ក ខ្ខ គ្គ ឃ្ឃ ង្ង

ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ

ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ

ត្ត ថ្ថ ទ្ទ ធ្ធ ន្ន

ប្ប ផ្ផ ព្ព ភ្ភ ម្ម

យ្យ រ្រ ល្ល វ្វ ស្ស ហ្ហ ឡ្ឡ អ្អ

*ចំណាំ :* - ចំពោះព្យញ្ជនៈ ញ មានជើងពីរគឺ " ◌្ញ " និង " ◌្ញ "

- ចំពោះជើង " ◌្ឡ " មិនដែលប្រើទេ ។

## *លំហាត់*

ចូរគូសភ្ជាប់តួព្យញ្ជនៈទៅនឹងជើងរបស់វា ។

| | | | | | |
|---|---|---|---|---|---|
| គ | ◌្ណ | ក | ◌្ប | ជ | ◌្ជ |
| ឆ | ◌្គ | ដ | ◌្ក | រ | ◌្ឋ |
| ណ | ◌្ទ | ប | ◌្ន | ខ | ◌្ឍ |
| ទ | ◌្ឆ | ន | ◌្ដ | ឋ | ◌្ល |
| ផ | ◌្ឈ | ឃ | ◌្ឃ | ព | ◌្ខ |
| ភ | ◌្ហ | ថ | ◌្ម | ឍ | ◌្ព |
| ឈ | ◌្ផ | ម | ◌្ស | យ | ◌្រ |
| ហ | ◌្ភ | ស | ◌្ថ | ល | ◌្យ |

មេរៀនទី
៦៨

# ផ្ញើជើង ក្ដ ក្ប ក្ស ក្អ

ក្ដ ក្ដា ក្ដិ ក្ដី ក្ដឹ ក្ដឺ ក្បុ ក្បូ ក្បួ ក្បើ ក្បឿ ក្បៀ ក្សេ ក្សែ
ក្សៃ ក្សោ ក្សៅ ក្អុំ ក្អំ ក្អាំ ក្អះ ក្អុះ ក្អេះ ក្អោះ

ក្ដី ក្ដាន់ ក្ដាម ក្ដិច ក្ដិប ក្ដួច

ក្បង់ ក្បាល ក្បឿង ក្សេម

ក្អក ក្អម ក្អែប ក្អាត់ ក្អុក

ក្ដារខៀន ទូកក្ដោង ចងក្បិន

ក្បោះក្បាយ ក្សេមក្សាន្ដ

កូនក្អែកបោះពួយលើទូកក្ដោង ។

កូនក្ដាមវារក្បែរក្អមដាក់កូនក្អាត់ ។



ក្អម

# មេរៀនទី ៦៩ ផ្ញើជើង ក្វ ក្ន ក្ម ក្រ ក្ល

ក្វ ក្វា ក្វិ ក្វី ក្វឹ ក្វឺ ក្នុ ក្នូ ក្នួ ក្មើ ក្មឿ ក្មៀ ក្មេ ក្មែ
ក្មៃ ក្មោ ក្មៅ ក្រុំ ក្រំ ក្រាំ ក្លះ ក្លុះ ក្លេះ ក្លោះ

ក្វក់ ក្វាន ក្វោក ក្នុង ក្នាញ់ ក្រុង

ក្រប ក្រោយ ក្រៅ ក្លិន ក្លែប

ក្វិចក្វក់ ក្និកក្នក់ ក្មេងក្មាង

ក្រចក ក្រសារ ក្រអូប

ក្វានដើរដកកក្វិចក្វក់ ។

ពូក្រឿនដាំក្រូចនៅក្រចេះ ។

ក្មេងៗរត់លេងក្រោមដើមក្វោក ។



ក្វោក



ក្រសារ

# រៀនសាឡើងវិញ

ក្ដារខៀន ទូកក្ដោង ក្បោះក្បាយ ក្បូរក្បាច់

ក្សេមក្សាន្ត ក្អិកក្អក់ ក្មេងក្មាង ក្រចក ក្រថៅ

ក្រសាំង ក្រៀមក្រោះ ក្លាហាន ក្លែងក្លាយ ក្រអូប

កុំចាប់កូនក្អាត់ដាក់ក្នុងក្អម ។

ក្រសារទំលើដើមក្រសាំងចាំចាប់ចំណី ។

*លំហាត់*

១. ចូរសរសេរពាក្យឱ្យត្រូវនឹងរូបខាងក្រោម ៖



.............



.............



.............

២. ចូរសរសេរពាក្យដែលផ្សំដោយ ក្ប ក្រ ឱ្យបានបីៗពាក្យ ។

| | |
|---|---|
| ក្ប -ក្បាល | ក្រ -ក្រចក |
| .......... | .......... |
| .......... | .......... |
| .......... | .......... |

មេរៀនទី
៧០

# ផ្ញើជើង ខ្ច ខ្ញ ខ្ដ ខ្ន

ខ្ច ខ្ចា ខ្ចិ ខ្ចី ខ្ចឹ ខ្ចឺ ខ្ញុ ខ្ញូ ខ្ញួ ខ្ញើ ខ្ញឿ ខ្ញៀ ខ្ដេ ខ្ដែ
ខ្ដៃ ខ្ដោ ខ្ដៅ ខ្នុំ ខ្នំ ខ្នាំ ខ្នះ ខ្នុះ ខ្នេះ ខ្នោះ

ខ្ចី ខ្ចប់ ខ្ចៅ ខ្ចោះ ខ្ញី ខ្ញាំ ខ្ញុំ ខ្ញាក ខ្ញុង ខ្មែរ

ខ្ដត ខ្នង ខ្នាត ខ្នុរ ខ្នើយ ខ្នោស

ខ្ចាត់ខ្ចាយ ខ្ញៀវខ្ញារ ខ្នះខ្នែង



ខ្ចៅ

តាខ្ញុំខ្នះខ្នែងដាំខ្ញី ។

ចាបយំខ្ញៀវខ្ញារលើមែកឈើ ។

ក្មេងៗលេងខ្ញៀវខ្ញារក្បែរគល់ខ្នុរ ។



ខ្ញី



ក្មេងៗលេងខ្ញៀវខ្ញារក្បែរគល់ខ្នុរ ។

មេរៀនទី
៧១

# ផ្ញើជើង ខ្ម ខ្យ ខ្ល ខ្វ ខ្ស

ខ្ម ខ្មា ខ្មិ ខ្មី ខ្មឹ ខ្មឺ ខ្យុ ខ្យូ ខ្យួ ខ្យើ ខ្លឿ ខ្លៀ ខ្លេ ខ្លែ
ខ្លៃ ខ្វោ ខ្វៅ ខ្វុំ ខ្វំ ខ្វាំ ខ្សះ ខ្សុះ ខ្សេះ ខ្សោះ

ខ្មៅ ខ្មាំង ខ្យង ខ្យល់ ខ្លា ខ្លី ខ្លួយ

ខ្លែង ខ្វិន ខ្សត់ ខ្សាច់ ខ្សឹប ខ្សែ

ខ្មៅដៃ ទាខ្វៃ ខ្សែដៃ ខ្មោះខ្មួរ ខ្លារខិន

ក្មេងខ្លះមិនចេះកាន់ខ្មៅដៃខ្លីសរសេរទេ ។

គេនិទានថាចៅខ្វាក់ ចៅខ្វិនមិនខ្លាចចាប់ខ្លា ។



ខ្លារខិន



ខ្មៅដៃ



ទាខ្វៃ

# រៀនសាឡើងវិញ

ខ្ចាត់ខ្ចាយ ខ្ញៀវខ្ញារ ខ្នះខ្នែង ដីខ្សាច់ ខ្សែដៃ

ខ្មៅដៃ ខ្យងហៀន ខ្យាដំរី ទាខ្វៃ ខ្សឹកខ្សួល

ខ្ជះខ្ជាយ ខ្ទេចខ្ទី ខ្ពង់ខ្ពស់ ខ្លបខ្លាច ខ្វាត់ខ្វែង

ចៅទឹងខ្មៅខ្នងខ្ញុំ ។ ក្អែកយំខ្វកៗលើមែកខ្វិត ។

កុំខ្ជីខ្ជាក្នុងការងារ ។ ពូសេកដាំខ្ទឹមនៅក្បែរខ្ទម ។

## *លំហាត់*

១. ចូរបំពេញជើងព្យញ្ជនៈពីក្រោមពាក្យ ។

ទាខៃ ខៅដៃ ខ្ញៀវខារ ខាត់ខ្ចាយ ខ្នះខែង

...... ...... ...... ...... ......

២. ចូររៀបពាក្យខាងក្រោមឱ្យបានជាល្បះត្រឹមត្រូវ ។

| ក្អែល ។ | កុំ | ដុស | ខ្ជិល |
|---|---|---|---|

# មេរៀនទី ៧២ ផ្ញើជើង គ្ន គ្ម គ្រ

គ្ន គ្នា គ្និ គ្នី គ្នឹ គ្នឺ គ្នុ គ្នូ គ្នួ គ្មើ គ្មឿ គ្មៀ គ្មេ គ្មែ
គ្មៃ គ្មោ គ្មៅ គ្រុំ គ្រំ គ្រាំ គ្រះ គ្រុះ គ្រេះ គ្រោះ

គ្នា គ្នេរ គ្មាន គ្រា គ្រូ គ្រុន

គ្រប គ្រាប់ គ្រឿង គ្រែ គ្រំ

គ្រួសារ គ្នីគ្នា គ្រញូង គ្រប់គ្រាន់ គ្រវី

លោកគ្រូខ្ញុំពិសានំគ្រក់ ។

ខ្ញុំគេងមិនគ្រប់ម៉ោងកើតជាគ្រុន ។

គ្រួសារខ្ញុំពិគ្រោះគ្នានៅលើគ្រែ ។



គ្រួសារ



គ្រែ

មេរៀនទី ៧៣

# ផ្ញើជើង ឃ្វ ឃ្ន ឃ្ម ឃ្ល ឃ្យ

ឃ្វ ឃ្វា ឃ្វិ ឃ្វី ឃ្វឹ ឃ្វឺ ឃ្នុ ឃ្នូ ឃ្នួ ឃ្នើ ឃ្នឿ ឃ្មៀ ឃ្មេ ឃ្មែ
ឃ្មៃ ឃ្មោ ឃ្លៅ ឃ្លុំ ឃ្លំ ឃ្លាំ ឃ្យះ ឃ្យុះ ឃ្យេះ ឃ្យោះ

ឃ្វើច ឃ្នាប ឃ្នើស ឃ្មោះ ឃ្មុំ

ឃ្លង់ ឃ្លា ឃ្លាំ ឃ្លោក ឃ្លាំង ឃ្យាល

យង់ឃ្នង ឃ្មាតខ្មី ខ្លាឃ្មុំ

ឃ្លាតឃ្លា ឃ្លៀងឃ្លាត ក្រូចឃ្វិច

សុខឃ្យាលក្របី ។ តាសំដើរឃ្វើចៗ ។

ពូអ៊ុកវាយឃ្មោះ ។

ពូឃ្លំយកឃ្មុំនៅលើដើមក្រូចឃ្វិច ។


ឃ្លោក


សុខឃ្យាលក្របី ។


ឃ្មោះ

# រៀនសាឡើងវិញ

ក្តីក្តា គ្រញូង គ្រប់គ្រាន់ យង់ឃ្នង ឃ្មាតខ្មី
ខ្លាឃ្មុំ ឃ្លាតឃ្លា ឃ្លៀងឃ្លាត ក្រូចឃ្មិច
គ្រលេងគ្រលោងទំលើដើមក្រឡាញ់ ។
យើងនាំក្តីក្តាទៅឃ្លាំមើលឃ្លាំង ។
ពូឃ្លោកឃ្លានខ្លាំងដោយហូបមិនគ្រប់គ្រាន់ ។

*លំហាត់*

១. ចូរសរសេរពាក្យឱ្យត្រូវនឹងរូបខាងក្រោម ៖





............ ............ ............

២. ចូរសរសេរតាមអានរៀបចំអំពីល្បះ ។

មេរៀនទី
៧៤

# ចម្រៀង



## ពេលដើរទៅសាលា

ពេលដើរទៅសាលា ហៃអស់កុមារចូរអ្នកចងចាំ
ដើរអែបៗខាងស្តាំ លើចិញ្ចើមថ្នល់ទើបបានល្អ ។

មេរៀនទី ៧៥

# ផ្ញើជើង ច្ប ច្ន ច្យ ច្រ

ច្ប ច្បា ច្បិ ច្បី ច្បឹ ច្បឺ ច្នុ ច្នូ ច្នួ ច្នើ ច្នឿ ច្នៀ ចៀ្យ ចែ្យ
ចៃ្យ ចោ្យ ចៅ្យ ច្រុំ ច្រំ ច្រាំ ច្រេះ ច្រុះ ច្រេះ ច្រោះ

ច្បារ ច្បាប់ ច្នៃ ច្បុត ច្រត់

ច្រាន ច្រូត ច្រើន ច្រៀង

កូនច្បង សួនច្បារ កែច្នៃ ច្រមុះ

ច្រឡំ ច្របាច់ ច្រាស់ច្រាល់

យាយខ្ញុំដើរកាន់ឈើច្រត់។

រៀមច្បងយើងច្រៀងផងច្រូតផង។



យាយខ្ញុំដើរកាន់ឈើច្រត់។



សួនច្បារ

# មេរៀនទី ៧៦ ផ្ញើជើង ឆ្ក ឆ្វ ឆ្ដ ឆ្ន

ឆ្ក ឆ្កា ឆ្កិ ឆ្កី ឆ្កឹ ឆ្កឺ ឆ្វុ ឆ្វូ ឆ្វួ ឆ្វើ ឆ្វឿ ឆ្វៀ ឆ្ដេ ឆ្ដែ

ឆ្ដៃ ឆ្ដោ ឆ្ដៅ ឆ្នុំ ឆ្នំ ឆ្នាំ ឆ្នះ ឆ្នុះ ឆ្នេះ ឆ្នោះ

ឆ្កាង ឆ្ការ ឆ្កែ ឆ្កោក ឆ្វល់ ឆ្វាញ់ ឆ្វាយ

ឆ្ដុប ឆ្ដោ ឆ្នុក ឆ្នូត ឆ្នើម ឆ្នេរ ឆ្នាំង

ឆ្កែឆ្កួត ឆ្នេរខ្សាច់

ឆាខ្វីសាច់មាន់ឆ្វាញ់ណាស់។

ចៅគាពាក់អាវក្រហមឆ្អៅ។



ឆ្កែ



ឆ្នាំង

# មេរៀនទី ៧៧ ផ្ញើជើង ឆ្ម ឆ្ល ឆ្វ ឆ្អ

ឆ្ម ឆ្មា ឆ្មិ ឆ្មី ឆ្មឹ ឆ្មឺ ឆ្លុ ឆ្លូ ឆ្លួ ឆ្លើ ឆ្លឿ ឆ្លៀ ឆ្វេ ឆ្វែ

ឆ្វៃ ឆ្វោ ឆ្វៅ ឆ្អុំ ឆ្អំ ឆ្អាំ ឆ្អះ ឆ្អុះ ឆ្អេះ ឆ្អោះ

ឆ្មា ឆ្លង ឆ្លាត ឆ្លាម ឆ្លូញ ឆ្លូវ

ឆ្វេង ឆ្អល់ ឆ្អាប ឆ្អិន ឆ្អើម ឆ្អើរ

ឆ្មាបា ឆ្លងឆ្លើយ ជើងឆ្វេង

ឆ្អល់ពោះ ឆ្អេះឆ្អាប ឆ្អិនឆ្អៅ

ឆ្មាបារត់ឆ្លេឆ្លា ។

ឆ្លាំងឆ្ងាញ់មិនចាញ់ឆ្លូញ ។

ខ្ចៅវារគើមៗតាមឆ្នេរខ្សាច់ ។



ឆ្មា



ឆ្លាម

# រៀនសាឡើងវិញ

កូនច្បង សួនច្បារ កែច្នៃ ច្បុត ឆ្កែឆ្កួត ក្ដារឆ្នួន
ឆ្នេរខ្សាច់ ឆ្មាបា ឆ្នាំឆ្លូវ ឆ្លងឆ្លើយ ជើងឆ្វេង
ឆ្អិនឆ្អៅ ច្របូកច្របល់

ពូសែមមិនចេះឆ្អើងឆ្អៃ ។
ក្មេងឆ្លាតនៅឆ្ងាយពីឆ្កែឆ្កួត ។
មីងអឿនចេះច្រៀងអាយ៉ៃឆ្លើយឆ្លងយ៉ាងពីរោះ ។

*លំហាត់*

១. ចូរសរសេរពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ ។

ក. សួនច្ប ....

ខ. ឆ្នេរខ្ស ....

គ. ក្ដារឆ្ន

....

ឃ. ឆ្នាំឆវ

....

២. ចូរសរសេរតាមអានរៀបចំអំពីល្បះចំនួនពីរល្បះ ។

មេរៀនទី ៧៨

# ផ្ញើជើង ជ្រ ជ្វ

ជ្រ ជ្រា ជ្រិ ជ្រី ជ្រឹ ជ្រឺ ជ្រុ ជ្រូ ជ្រួ ជ្រើ ជ្រឿ ជ្រៀ

ជ្វេ ជ្វែ ជ្វៃ ជ្វោ ជ្វៅ ជ្វុំ ជ្វំ ជ្វាំ ជ្វះ ជ្វុះ ជ្វេះ ជ្វោះ

ជ្រក ជ្រក់ ជ្រាប ជ្រាយ ជ្រឹង ជ្រុល ជ្រុះ ជ្រូក ជ្វា

ជ្រលក់ ជ្រមុជ ជ្រើសរើស ជ្រោមជ្រែង

ជ្រុងជ្រោយ ដំឡូងជ្វា

ជ្រោះនេះជ្រៅណាស់ ។

ជ្រឹងជាច្រើនទំលើមែកជ្រៃ ។

មីងជ្រឹមហូបជ្រក់ចេកជ្វា ។



ជ្រឹង



ជ្រូក

# មេរៀនទី ៧៩ ផ្ញើជើង ឈ្វ ឈ្ន ឈ្ម ឈ្ល ឈ្យ

ឈ្វ ឈ្វា ឈ្វិ ឈ្វី ឈ្វឹ ឈ្វឺ ឈ្នុ ឈ្នូ ឈ្នួ ឈ្នើ ឈ្នឿ ឈ្មៀ ឈ្មេ
ឈ្មែ ឈ្មៃ ឈ្មោ ឈ្មៅ ឈ្លុំ ឈ្លំ ឈ្លាំ ឈ្យះ ឈ្យុះ ឈ្យេះ ឈ្យោះ

ឈ្វុយ ឈ្វោក ឈ្នាង ឈ្នាន់ ឈ្នួញ ឈ្មោល
ឈ្មោះ ឈ្លី ឈ្លូស ឈ្លើង ឈ្យាត
ឈ្វុយឈ្វប់ ឈ្លានពាន ឈ្លាសវៃ
រំដួលចោលក្លិនឈ្វុយឈ្វប់ ។
កូនឈ្លូសឈ្មោលបោលរកមេវា ។
ជ្រូកឈ្មុសរងដំឡូងជ្វាដេញមិនឈ្នះ ។



ឈ្លូស



ឈ្នាង

# មេរៀនទី ៨០ ផ្ញើជើង ត្ប ត្ន ត្រ

ត្ប ត្បា ត្បិ ត្បី ត្រឹ ត្រឺ ត្បុ ត្បូ ត្បួ ត្នើ ត្នឿ ត្នៀ ត្នេ
ត្នែ ត្នៃ ត្នោ ត្នៅ ត្រុំ ត្រំ ត្រាំ ត្រះ ត្រុះ ត្រេះ ត្រោះ

ត្បាញ ត្បូង ត្នាត ត្នោង ត្រាវ ត្រួត ត្រប់

ត្នាតភ្លើង ត្រួតត្រា ត្រឡាច ត្បាល់ក្លឿង ត្រកួន

ត្នាតរត់ក្បែរដើមត្រែង ។

ត្រដក់ឈរចាំចាប់ត្រីក្នុងបឹង ។



ត្នាតភ្លើង



ត្បាល់ក្លឿង

# រៀនសាឡើងវិញ

ជ្រលក់ ជ្រមុជ ជ្រើសរើស ជ្រោមជ្រែង
ដំឡូងជ្វា ឈ្មុយឈ្ងប់ ឈ្លាសវៃ ឈ្មុសឈ្មុល
ត្បាល់ក្តៀង ត្រឡាច

មីងសានជ្រើសរើសដំឡូងជ្វា ។
កីឡាករខ្មែរលេងបាល់ឈ្នះគេ ។

*លំហាត់*

១. ចូរសរសេរពាក្យដែលផ្សំដោយ ជ្រ ឈ្ល ត្ប ឱ្យបានពីរពាក្យ ។

*ឧទាហរណ៍ :* ជ្រូក ឈ្លើ ត្បូង

ក. ជ្រ ...... ក. ជ្រ ......

ខ. ឈ្ល ...... ខ. ឈ្ល ......

គ. ត្ប ...... គ. ត្ប ......

២. ចូរសរសេរអក្សរផ្គុំអំពីពាក្យ “លេង” ។

# មេរៀនទី ៨១ ផ្ញើជើង ថ្ក ថ្ង ថ្ន ថ្ម ថ្ល ថ្វ

ថ្ក ថ្កា ថ្កិ ថ្កី ថ្កឹ ថ្កឺ ថ្ងុ ថ្ងូ ថ្ងួ ថ្ងើ ថ្ងឿ ថ្ងៀ ថ្ងេ ថ្ងែ

ថ្នៃ ថ្នោ ថ្នៅ ថ្លុំ ថ្លំ ថ្លាំ ថ្លះ ថ្វុះ ថ្វេះ ថ្វោះ

ថ្កល់ ថ្កូវ ថ្ងាស ថ្ងៃ ថ្នល់ ថ្នាក់

ថ្នាល ថ្ម ថ្មី ថ្លា ថ្លង់ ថ្លើម ថ្វី ថ្វាយ

ថ្កើងថ្កាន ថ្ងួចថ្ងូរ ថ្នាក់ថ្នម ថ្លៃថ្នូរ ថ្មោងថ្មី ថ្លៃថ្លា

ម៉ែថ្នាក់ថ្នមកូនដោយចិត្តថ្លៃថ្លា ។

ត្បូងថ្មមិនទាន់ច្នៃ គេមិនដឹងថ្លៃទេ ។



ផ្លែថ្កូវ

# មេរៀនទី ៨២ ផ្ញើជើង ទ្រ ទ្វ

ទ្រ ទ្រា ទ្រិ ទ្រី ទ្រឹ ទ្រឺ ទ្រុ ទ្រូ ទ្រួ ទ្រើ ទ្រឿ ទ្រៀ

ទ្វេ ទ្វែ ទ្វៃ ទ្វោ ទ្វៅ ទ្វុំ ទ្វំ ទ្វាំ ទ្វះ ទ្វុះ ទ្វេះ ទ្វោះ

ទ្រូ ទ្រុង ទ្រើង ទ្វីប ទ្វេ ទ្វារ

ទ្រាំទ្រ ទ្រេតទ្រោត ទ្រុឌទ្រោម ទ្វីបលោក

ទ្វារនេះចាស់ទ្រុឌទ្រោម ។

អ៊ុំសឿនជួសជុលទ្រុងជ្រូក ។



ទ្រូ



អ៊ុំសឿនជួសជុលទ្រុងជ្រូក ។

# រៀនសាឡើងវិញ

ថ្កើងថ្កាន ថ្ពួចថ្ពូរ ថ្នាក់ថ្នម ថ្លៃថ្នូរ ទ្វារផ្ទះ

ថ្លៃថ្លា ទ្រាំទ្រ ទ្វីបលោក ថ្មកែវ

ទោចយំថ្ពួចថ្ពូរ ។

ថ្មកែវលក់បានថ្លៃ ។

ម៉ែថ្នាក់ថ្នមកូនដោយចិត្តថ្លៃថ្លា ។

*លំហាត់*

១. ចូរសរសេរពាក្យឱ្យត្រូវនឹងរូបខាងក្រោម ៖







............ ............ ............

២. ចូរសរសេរតាមអានត្រួតពិនិត្យ ។

# មេរៀនទី ៨៣ ផ្ញើជើង ធ្ង ធ្ន ធ្ម

ធ្ង ធ្ងា ធ្ងិ ធ្ងី ធ្ងឹ ធ្ងឺ ធ្ងុ ធ្ងូ ធ្ងួ ធ្នើ ធ្នឿ ធ្នៀ ធ្នេ ធ្នែ
ធ្នៃ ធ្នោ ធ្នៅ ធ្មុំ ធ្មំ ធ្មាំ ធ្មះ ធ្មុះ ធ្មេះ ធ្មោះ

ធ្ងន់ ធ្នាក់ ធ្នូ ធ្នើរ ធ្មេញ ធ្មុង ធ្មៃ

ធ្ងន់ធ្ងរ ធ្មេញឈើ ធ្មុងត្រី គ្រូធ្មប់

សំឈើធ្មេញធ្ងន់ធ្ងរ ។

ការងារដាំធ្មៃមិនធ្ងន់ធ្ងរទេ ។



ធ្នូ



ធ្មេញ



ធ្នើរ

# មេរៀនទី ៨៤ ផ្ញើជើង ប្ដ ប្រ ប្ល ប្អ

ប្ដ ប្ដា ប្ដិ ប្ដី ប្ដឹ ប្ដឺ ប្រុ ប្រូ ប្រួ ប្រើ ប្រឿ ប្រៀ ប្រេ ប្លែ
ប្លៃ ប្លោ ប្លៅ ប្អុំ ប្អំ ប្អាំ ប្អះ ប្អុះ ប្អេះ ប្អោះ

ប្ដី ប្ដឹង ប្ដូរ ប្រក់ ប្រើ ប្រេះ ប្លែក ប្អូន

ប្រកួត ប្រកាស កំប្រុក

ប្រែប្រួល ប្លេះប្លោះ ប្រើប្រាស់

កុមារប្រកួតគូរគំនូរ ។

ប្អូនប្រុសខ្ញុំប្ដូរខោប្រផេះ ។

ពូប្រឹមមិននិយាយប្លេះប្លោះ ។



កំប្រុក





កុមារប្រកួតគូរគំនូរ ។

មេរៀនទី
៨៥

# ផ្ញើជើង ផ្ក ផ្ង ផ្ដ ផ្ញ

ផ្ក ផ្កា ផ្កិ ផ្កី ផ្កឹ ផ្កឺ ផ្ងុ ផ្ងូ ផ្ងួ ផ្ញើ ផ្ញឿ ផ្ញៀ ផ្ដេ ផ្ដែ
ផ្ដៃ ផ្ដោ ផ្ដៅ ផ្ងុំ ផ្ងំ ផ្ញាំ ផ្ញះ ផ្ញុះ ផ្ដេះ ផ្ញោះ

ផ្កា ផ្កាប់ ផ្កាយ ផ្ញារ ផ្ញូត ផ្ដិត ផ្ញើ

ផ្កាត្រែង ផ្ដិតផ្ដង់ ផ្កាឈូក

ក្មួយៗគូររូបផ្កាដោយផ្ដិតផ្ដង់ ។

ពេលយប់ផ្កាយរះគ្រប់ទិសទី ។

ម៉ែផ្ញើផ្ញៀរទៅបងប្អូននៅទីក្រុង ។



ផ្កាឈូក



ផ្កាយ

# រៀនសាឡើងវិញ

ធ្ងន់ធ្ងរ  ប្រកែក ប្រកួត ផ្កាត្រែង ផ្គិតផ្គង់

ម៉ែផ្ងូតទឹកកូនដោយថ្នមៗ ។

ការងារដាំធ្មៃមិនធ្ងន់ធ្ងរទេ ។

កីឡាករខ្មែរប្រកួតឈ្នះគេ ។

*លំហាត់*

១. ចូរជ្រើសរើសពាក្យឱ្យត្រូវនឹងរូប ។

ក. ផ្កា
ខ. ផ្កាយ
គ. ផ្គិត



ក. ធ្មុង
ខ. ធ្មូ
គ. ធ្មេញ



២. ចូរសរសេរតាមអានត្រួតពិនិត្យ ។

# មេរៀនទី ៨៦ ផ្ញើជើង ផ្ដ ផ្ត ផ្ទ ផ្ល ផ្ស ផ្អ

ផ្ដ ផ្ដា ផ្ដិ ផ្ដី ផ្ដឹ ផ្ដឺ ផ្ទុ ផ្ទូ ផ្ទួ ផ្ទើ ផ្ទឿ ផ្លៀ ផ្លេ ផ្លែ

ផ្លៃ ផ្សោ ផ្សៅ ផ្សុំ ផ្សំ ផ្អាំ ផ្អះ ផ្អុះ ផ្អេះ ផ្អោះ

ផ្ដល់ ផ្ដើម ផ្ដៅ ផ្ដិល ផ្លិត ផ្លូវ ផ្លែ

ផ្ទត់ ផ្ទូរ ផ្អក ផ្សិត ផ្សោត ផ្សារ

ផ្ដាំផ្ញើ ផ្ដួចផ្ដើម ផ្សែផ្សំ

ពូជុំបក់ផ្លិតក្រដាស ។

តាលាំផ្ដាំចៅកែឱ្យចេះថែផ្សោត ។



ផ្សិត



ផ្សោត

# មេរៀនទី ៨៧ ផ្ញើជើង ព្ន ព្យ ព្រ ព្ល

ព្ន ព្នា ព្និ ព្នី ព្នឹ ព្នឺ ព្យុ ព្យូ ព្យួ ព្យើ ព្យឿ ព្យៀ ព្រេ

ព្រែ ព្រៃ ព្រោ ព្រៅ ព្លុំ ព្លំ ព្លាំ ព្លះ ព្លុះ ព្លេះ ព្លោះ

ព្នង ព្នៅ ព្យុះ ព្យួរ ព្រះ ព្រាត់ ព្រាប ព្រឹង ព្រឹក ព្រូន

ព្រួយ ព្យាបាល ព្យាយាម ព្រលឹម ព្រោងព្រាត

កូនព្រាបហើរព្រោងព្រាត ។

រាល់ព្រឹកចៅព្រំព្យាយាមក្រោកពីព្រលឹមទៅរើស

ផ្លែព្នៅ ។



ព្រះ



ព្រាប

# មេរៀនទី ៨៨ ផ្ញើជើង ភ្វ ភ្ជ ភ្ញ ភ្ន ភ្ល

ភ្វ ភ្វា ភ្វិ ភ្វី ភ្វឹ ភ្វឺ ភ្ជុ ភ្ជូ ភ្ជួ ភ្ជើ ភ្ជឿ ភ្ញៀ ភ្ញេ

ភ្ញែ ភ្ញៃ ភ្ញោ ភ្នៅ ភ្នុំ ភ្នំ ភ្នាំ ភ្លះ ភ្លុះ ភ្លេះ ភ្លោះ

ភ្វើយ ភ្ជួរ ភ្ជុំ ភ្ជាប់ ភ្ញាស់ ភ្ញៀវ

ភ្នែក ភ្នំ ភ្នក់ ភ្លឺ ភ្លើង ភ្លេង ភ្លៅ

ភ្ញាក់ផ្អើល ភ្នំពេញ ភ្លេចភ្លាំង

រដូវភ្ជុំមានភ្ញៀវច្រើន ។

ភ្ញៀវតែងភ្ញាក់ផ្អើលពេលឃើញប្រាសាទខ្មែរ ។

ពូសុកភ្ញាក់ពីព្រលឹមទៅភ្ជួររាស់ដីក្បែរជើងភ្នំ ។



ភ្ជួររាស់



ភ្នំពេញ

# រៀនសាឡើងវិញ

ផ្គួចផ្ដើម ផ្ដាំផ្ញើ ផ្សែផ្សំ ផ្សះផ្សា ផ្លែផ្ទៀវ
ផ្គាប់ផ្គុន ព្យាបាល ព្រះពាយ ភ្ញាក់ផ្អើល
ភ្លេចភ្លាំង ព្រោងព្រាត ផ្លែញ៉ៅជ្រុះ
ភ្នំពេញមានភ្លើងភ្លឺព្រោងព្រាត ។
តាព្រំផ្គួចផ្ដើមធ្វើបុណ្យផ្កាមុនរដូវភ្លៀងធ្លាក់ ។

*លំហាត់*

១. ចូរសរសេរបំពេញពាក្យខាងក្រោមឱ្យបាន
ត្រឹមត្រូវ ។

ក. ព្រះពា ខ. ផះផ្សា

គ. ព្យបាល ឃ. ភ្នពេញ

២. ចូរសរសេរតាមអានរៀបចំចំនួនប្រាំពាក្យនិងពីរ
ល្បះ ។

មេរៀនទី
៨៩

# ផ្ញើជើង ម្ក ម្ខ ម្ច ម្ត

ម្ក ម្កា ម្កិ ម្កី ម្កឹ ម្កឺ ម្ខុ ម្ខូ ម្ខួ ម្ខើ ម្ខឿ ម្ខៀ ម្ចេ

ម្ចែ ម្ចៃ ម្ចោ ម្ចៅ ម្តុំ ម្តំ ម្តាំ ម្តះ ម្តុះ ម្តេះ ម្តោះ

ម្កាក់ ម្ចាស់ ម្តាយ ម្តុំ

ផ្លែម្កាក់ ម្ចាស់ដី

គ្រួសារខ្ញុំទៅលេងសៀមរាបម្តងម្កាល ។

ម្ចាស់ដីនេះឈឺដៃម្ខាង ។

ម្តាយខ្ញុំទិញផ្លែម្កាក់មកផ្ញើក្មេងៗ ។



ម្កាក់



ពូសៀកឈឺដៃម្ខាង ។

មេរៀនទី ៩០

# ផ្ញើជើង ម្ង ម្ជ ម្ញ ម្ទ

ម្ង ម្ងា ម្ងិ ម្ងី ម្ងឹ ម្ងឺ ម្ជុ ម្ជូ ម្ជួ ម្ជើ ម្ជឿ ម្ជៀ ម្ញេ

ម្ញែ ម្ញៃ ម្ញោ ម្ញៅ ម្ទុំ ម្ទំ ម្ទាំ ម្ទះ ម្ទុះ ម្ទេះ ម្ទោះ

ម្ជូរ ម្ជុល ម្ទេស

ម្ជុលខ្ទាស់ ម្ទេសឆ្អើរ

មីងចាន់ហាលម្ទេសឆ្អើរ ។

ចៅជាជ្រុះម្ជុលខ្ទាស់ក្នុងថ្នាលម្ទេស ។

ខ្ញុំចូលចិត្តហូបត្រីឆ្អើរបុកម្ជូរអំពិល ។



ម្ជុលខ្ទាស់



ម្ទេស

# មេរៀនទី ៩១ ផ្ញើជើង ម្ន ម្ភ ម្យ ម្រ ម្ល

ម្ន ម្នា ម្និ ម្នី ម្នឹ ម្នឺ ម្ភុ ម្ភូ ម្ភួ ម្ភើ ម្ភឿ ម្យៀ ម្យេ
ម្យែ ម្យៃ ម្យោ ម្រៅ ម្រុំ ម្រំ ម្រាំ ម្លះ ម្លុះ ម្លេះ ម្លោះ

ម្នាស់ ម្ភៃ ម៉្យាង ម្រាម ម្រះ ម្រេច ម្លូ ម្លិះ
ម្នីម្នា ផ្លែម្នាស់ ម្រាមដៃ ម្រះព្រៅ ម្លប់ជ្រៃ
នាងណាគម្នីម្នាទៅបេះផ្លែម្នាស់។
គេមិនដាំម្រេច ម្រះ និងម្លូក្រោមម្លប់ទេ។


ម្នាស់


ម្រះ

# រៀនសាឡើងវិញ

| | | |
|---|---|---|
| ម្ទីម្ទា | ម្រះព្រៅ | ម្ដេចម្ដា |
| ម្រិកម្រ៉ូក់ | ម្រេចស | ម្លូព្រៃ |

កូនៗមិនត្រូវប្រកាន់ឫកម្រិកម្រ៉ូក់ទេ ។

មឹងព្រឹមម្ទីម្ទាទៅបេះត្រួយម្រះព្រៅ ។

*លំហាត់*

១. ចូរសរសេរបំពេញពាក្យខាងក្រោមឱ្យបានត្រឹមត្រូវ ។

ក. ម្លូ ..... ខ. ម្រេច ..... គ. ម្រះ .....

ឃ. ម្ទី ..... ង. ម្រិក .....

២. ចូរសរសេរតាមអានត្រួតពិនិត្យ ។

# មេរៀនទី ៩២ ផ្ញើជើង ល្ខ ល្ប ល្ហ ល្អ

ល្ខ ល្ខា ល្ខិ ល្ខី ល្ខឹ ល្ខឺ ល្បុ ល្បូ ល្បួ ល្បើ ល្បឿ ល្បៀ ល្ហេ ល្ហែ

ល្ហៃ ល្ហោ ល្ហៅ ល្អុំ ល្អំ ល្អាំ ល្អះ ល្អុះ ល្អេះ ល្អោះ

ល្ខោន ល្បឿន ល្ហុង ល្អ ល្អី ល្អិត

ល្ខោនខោល ល្បីល្បាញ ល្ហិតល្ហៃ

ល្បិចកល ល្អិតល្អន់

នារីប្រឹងប្រែងធ្វើការយ៉ាងល្អិតល្អន់ ។

ក្រុមល្ខោននេះមានឈ្មោះល្បីល្បាញយូរឆ្នាំហើយ ។



ល្ខោន

# មេរៀនទី ៩៣ ផ្ញើជើង ស្ក ស្ដ ស្ល ស្ប ស្រ

ស្ក ស្កា ស្កិ ស្កី ស្កឹ ស្កឺ ស្ដុ ស្ដូ ស្ដួ ស្ដើ ស្ដឿ ស្លៀ ស្លេ ស្លែ ស្លៃ

ស្លោ ស្បៅ ស្បុំ ស្បំ ស្បាំ ស្រះ ស្រុះ ស្រេះ ស្រោះ

ស្កក ស្ករ ស្គូវ ស្ដៅ ស្ដាយ ស្ដាំ ស្លិត

ស្បែក ស្រែ ស្រូវ ស្រះ

ស្កប់ស្កល់ ស្កឹមស្កៃ ស្លានទូត

ស្លិតស្លេរ ស្រុកស្រែ ស្បែកជើង

ស្រីៗស្រុកស្រែពូកែញាំស្ដៅ ។

ម្ដាយខ្ញុំទៅផ្សារទិញស្បង់ ស្បែកជើង និងស្ករ

ប្រគេនលោក ។



ស្ករផែន



ស្បែកជើងផ្ទាត់



ស្រុកស្រែ

# មេរៀនទី ៩៤ ផ្ញើជើង ស្ង ស្ន ស្ម ស្ល ស្វ ស្អ

ស្ង ស្ងា ស្ងិ ស្ងី ស្ងឹ ស្ងឺ ស្នុ ស្នូ ស្នួ ស្នើ ស្មឿ ស្មៀ ស្មេ ស្មែ

ស្លែ ស្លោ ស្លៅ ស្វុំ ស្វំ ស្វាំ ស្អះ ស្អុះ ស្អេះ ស្អោះ

ស្ងាត់ ស្ងួត ស្នាច ស្និត ស្នប់ ស្មើ ស្មៅ

ស្លា ស្លឹក ស្វា ស្វាយ ស្វិត ស្អាត ស្អែក

ស្ងៀមស្ងាត់ ស្នាដៃ ស្លូតបូត ស្លាបព្រា

ស្វិតស្វាញ ស្វះស្វែង ស្វាហាប់ ស្អាតបាត

មីងខុមបោចស្មៅក្នុងស្រែយ៉ាងស្ងៀមស្ងាត់ ។

សិស្សល្អមានចិត្តស្លូតបូត ស្វាហាប់ និងមាន ស្នាដៃល្អ ។



ស្វាយ



ស្លាបព្រា



ស្វា

# រៀនសាឡើងវិញ

ល្ហោនខោល ល្បីល្បាញ ល្ហិតល្ហៃ ល្អិតល្អន់

ស្កររគ្នោត ស្ងៀមស្ងាត់ ស្ងប់ស្ងែង ស្ដិតស្ដេរ

ស្នាដៃ ស្បែកជើង ស្រុកស្រែ ស្លូតបូត ស្វះស្វែង

ស្វាហាប់ ស្វាមី ស្វិតថៅ ស្វិតស្វាញ

តាសោមឈើស្លែកស្លាំង ។

ព្រឹកនេះ ពុកនាំកូនក្មួយដាំដើមស្ដៅ ។

*លំហាត់*

ចូរសរសេរតាមអានរៀបចំចំនួនប្រាំពាក្យ និង

ពីរល្បះ ។

# មេរៀនទី ៩៥ ព្យាង្គតម្រួត ង្ក ង្ខ ង្វ ង្ស ង្ហ ង្អ

បង្កង បង្កួយ បង្កើត បង្ការ អង្ករ អង្កាម

សង្កេត ចង្កា កង្កែប ចង្កៀង ចង្កេះ ចង្កូម

ចង្កូត សង្ខារ បង្ខំ បង្វេច បង្វិល បង្វែរ

រង្វាន់ វង្វេង សង្វាត អង្វរ កង្ហារ បង្ហាញ

ចង្អេរ ចង្អើរ បង្អាក់ បង្អែម បង្អួច បង្អង់

សង្ស័យ វង្សត្រកូល អង្សា

សង្ហាសង្វាតសិក្សាមិនបង្អង់ ។

បង្កួយលោតតោងបង្អួចធ្លាក់ក្នុងចង្អេរអង្ករ ។



កង្កែប



ចង្អេរ



ចង្កៀង

មេរៀនទី
៩៦

# ព្យាង្គតម្រួត ង្គ ង្ឃ ជ្រ

គង្គា គីង្គក់ បង្គា បង្គន់ បង្គី បង្គោល

ជង្គង់ អង្គុយ សង្ឃឹម មង្ឃុត ពង្រីង ពង្រាយ

កង្កែបលោតក្បែរបង្គន់ជាន់ចំបង្គី ។

ចៅកឹមអង្គុយក្នុងអង្រឹង ។

តារាសង្ឃឹមថាបានញ៉ាំផ្លែមង្ឃុត ។



បង្គា



បង្គន់



មង្ឃុត



គីង្គក់

# រៀនសាឡើងវិញ

បង្កង បង្កួយ ចង្កៀង អង្ករ បង្គី មង្ឃុត សង្ឃឹម

ជង្រុក ពង្រឹង អង្រុត រង្វាន់ សង្វាត គង្វាល អង្វរ

សង្ស័យ កង្ហារ បង្ហាញ វង្វេង បង្វិល ចង្អេរ

បង្អែម បង្អាប់ បង្អង់

ម៉ែយកចង្អេរទៅអុំអង្ករនៅជិតជង្រុក ។

ពុកអុជចង្កៀងដើម្បីអង្គុយពិសាបង្អែម ។

*លំហាត់*

១. ចូរសរសេរពាក្យឱ្យត្រូវនឹងរូបខាងក្រោម ៖

   

.......... .......... .......... ..........

២. ចូរសរសេរអក្សរផ្គង់អំពីពាក្យ “ បាល់ ” ។

# មេរៀនទី ៩៧ ព្យាង្គតម្រួត ញ្ច ញ្ឆ ញ្ជ ញ្ឈ ញ្ញ

កញ្ចក់ កញ្ចែ ចិញ្ចៀន ចិញ្ចឹម ចិញ្ចើម បញ្ចប់

បញ្ចុក បញ្ចូល បញ្ចេញ កញ្ឆែត បញ្ឆិត

បញ្ឆោត បញ្ជី ជញ្ជីង កញ្ជើ ជញ្ជាំង

ជញ្ជូន បញ្ឈរ បញ្ឈប់ កញ្ញា បញ្ញើ

កញ្ញាជញ្ជូនកញ្ជើជាមួយឪពុក ។

នំបញ្ចុកដាក់កញ្ឆែតមានរសជាតិឆ្ងាញ់ ។



ជញ្ជីង



ចិញ្ចៀន

មេរៀនទី ៩៨

# ព្យាង្គតម្រួត ណ្ដ ណ្ណ ណ្ឌ

កណ្ដាប់ កណ្ដាល កណ្ដូប កណ្ដឹង កណ្ដុរ អណ្ដាត

បណ្ដាល បណ្ដោយ អណ្ដូង អណ្ដើក បណ្ណាល័យ

បណ្ណាគារ សណ្ឌាគារ

**ពូកៅដាក់អន្ទាក់ចាប់កណ្ដុរដែលស៊ីសណ្ដែក ។**

**យើងនាំគ្នាអានសៀវភៅនៅបណ្ណាល័យ ។**



កណ្ដូប



អណ្ដូង



អណ្ដើក

មេរៀនទី ៩៩

# ព្យាង្គតម្រួត ន្យ ន្ធ ន្ល ន្ស

សន្យា ពន្យារ បន្ធូរ កន្ធាយ កន្ធរ បន្លែ

ទន្លេ ពន្លឺ សន្សំ សន្សើម អន្សម ទន្សោង

ទន្សាយ បន្ទាប់ បន្សំ បន្ថយ

ទន្សាយស៊ីបន្លែនិងផឹកទឹកសន្សើម ។

ពេលយប់ពន្លឺចាំងព្រោងព្រាតតាមបណ្តោយទន្លេបួនមុខ ។



ទន្សាយ



ទន្សោង

# មេរៀនទី ១០០ ព្យាង្គតម្រួត ម្ប ម្ត ម្ភ ម្ម ម្រ ម្ល

សម្បក សម្ប៉ុរ សម្បូរ សម្ប៉ុក សម្បត្តិ ជម្ពូ សម្ពាយ

កម្ពស់ កុម្ភៈ សម្ភារៈ កម្ពុជា ចម្រៀង កម្រិត កម្រើក

ចម្លង ចម្លើយ កម្លាំង សម្លូ សម្លាប់ សម្លាញ់ កម្មករ

សម្លៀកបំពាក់

## ខែកុម្ភៈខ្ញុំទៅប្រឡងចម្រៀង។
## សម្លៀកបំពាក់ខ្ញុំស្អាតណាស់។



ជម្ពូ



សម្លៀកបំពាក់ខ្ញុំស្អាតណាស់។

# រៀនសាឡើងវិញ

ពន្យារ ពន្យល់ សន្ទឹក បន្លា បន្លែ ទន្សាយ សម្លក់ កម្ពុជា

ប្រទេសកម្ពុជា មានធនធានធម្មជាតិមានតម្លៃច្រើនសន្ធឹកសន្ធាប់ ។ ធនធានទាំងនោះមានដូចជា រ៉ែត្បូងថ្ម ព្រៃឈើ និងសត្វព្រៃជាដើម ។ យើងត្រូវស្រឡាញ់ប្រទេសយើង និងចូលរួមថែរក្សាការពារធនធានទាំងនោះឱ្យបានគង់វង្ស ។

*លំហាត់*

ចូរសរសេរតាមអានរៀបចំនួរកថាខណ្ឌខាងលើ ។

# មេរៀនទី ១០១ ព្យាង្គតម្រួត ង្ក្រ ង្គ្រ

អង្ក្រង អង្គ្រង ចង្ក្រង់ ចង្ក្រាន បង្ក្រាប
សង្គ្រាម សង្គ្រប សង្គ្រោះ បង្គ្រប់



ពូសុខដើរគោះអង្ក្រងក្នុងព្រៃអង្គ្រង ។ កូនស្រីច្បង គាត់យកពងអង្ក្រងពីលើចង្ក្រានទៅធ្វើជ្រក់ ។ គ្រួសារ គាត់ហូបត្រីកញ្ចុះអាំងជាមួយជ្រក់ពងអង្ក្រងយ៉ាង ឆ្ងាញ់ពិសា ។

មេរៀនទី ១០២

# ព្យាង្គតម្រួត ញ្ជ្រ ញ្ច្រ

កញ្ជ្រែង កញ្ជ្រឹក ចិញ្ជ្រាំ បញ្ជ្រក បញ្ជ្រាស កញ្ជ្រឹល

កញ្ច្រោង កញ្ច្រូក កញ្ច្រៀវ កញ្ច្រោល ជញ្ច្រាំង



ត្រីកញ្ច្រូក



កញ្ជ្រែង

ម្ដាយសុខាទិញត្រីកញ្ច្រូកមកពីផ្សារ ។ គាត់លាងត្រីដាក់ក្នុងកញ្ជ្រែងទុកធ្វើផ្អក ។ ផ្អកត្រីកញ្ច្រូកមានរសជាតិឆ្ងាញ់ ។

យើងត្រូវរួមគ្នាការពារពូជត្រីគ្រប់ប្រភេទឱ្យបានគង់វង្ស ។

# រៀនសាឡើងវិញ

ចង្ក្រាន សង្គ្រាម សង្គ្រោះ បង្ក្រាប កញ្ច្រែង កញ្ជ្រោង



កញ្ជ្រោង

ថ្ងៃមួយ ពូសំដើរគោះអង្ក្រងក្នុងព្រៃ ។ គាត់បានប្រទះឃើញសត្វកញ្ជ្រោងតូចមួយបាក់ជើង ក្រាបក្រោមដើមអង្គ្រង ។ គាត់ក៏ជួយសង្គ្រោះ កុំឱ្យអង្ក្រងខាំ ។

កញ្ជ្រោងជាសត្វកាចសាហាវ តែមានប្រយោជន៍សម្រាប់វិស័យទេសចរណ៍ ។

*លំហាត់*

ចូរសរសេរតាមអានត្រួតពិនិត្យ ។

មេរៀនទី ១០៣

# អ្នកគ្រូខ្ញុំ




អ្នកគ្រូខ្ញុំឈ្មោះណារី ។ គាត់មានអាយុសាមសិបប្រាំឆ្នាំ ។ គាត់មានរាងទាបទ្រមែ សក់វែងប្រាសស្មា ។

ខ្ញុំចូលចិត្តរៀនជាមួយអ្នកគ្រូខ្ញុំណាស់ ។

ខ្ញុំគោរព ស្រឡាញ់គាត់ ព្រោះគាត់ស្លូត ហើយមានគុណចំពោះខ្ញុំ ។

មេរៀនទី ១០៤

# សាលារៀនខ្ញុំ



សាលារៀនខ្ញុំ ជាសាលាកុមារមេត្រី ។ នៅមុខថ្នាក់រៀនមានដើមឈើផ្តល់ម្លប់ ដងទង់ជាតិ សួនផ្កា និងសួនជីវៈចម្រុះ ។ មុនពេលចូលថ្នាក់ យើងតែងបោសសំអាត និងស្រោចផ្ការាល់ពេល ។

ខ្ញុំស្រឡាញ់ចូលចិត្តសាលារៀនខ្ញុំណាស់ ព្រោះវាជាថ្នាលផ្តល់នូវចំណេះដឹងដល់យើងគ្រប់ៗគ្នា ។

# បទានុក្រម

## ក

កាផា (ន.) : ប្រភេទនៃសម្ភារៈប្រើប្រាស់ម្យ៉ាងមានរាងស្រដៀងនឹងជាល តែមានកម្ពស់ខ្ពស់ជាងនិងមានខ្សែសម្រាប់ស្ពាយពីក្រោយខ្នងដែលជនជាតិដើមភាគតិចនិយមប្រើ (នៅខេត្តរតនគិរីគេហៅថា កាផា ចំណែកឯនៅខេត្តមណ្ឌលគិរីគេហៅ ថាសាស់ ឬឆាស់)។

ការអំបោះ (កិ.) : មូរសរសៃអំបោះ។

កុកសាប់ (ន.) : ប្រភេទ ឈ្មោះកុកម្យ៉ាង។

ក្សិណ (ន.) : ពេល ស្របក់ រំពេច។

ក្សេម (គុ.) : សុខសប្បាយ។

## ខ

ខម (កិ.) : បើកភ្នែក បើកមាត់ លៀនអណ្តាត សម្តែងអាការគួរឱ្យខ្លាច។

(ន.) : ខ្មែរក្នុងសម័យបុរាណព្រេងនាយ។

(ន.) : ឈ្មោះអក្សរខ្មែរមួយបែប គឺអក្សរធំកាច់ជ្រុង(អក្សរខម)។

ខ្ទុង (ន.) : ឈ្មោះសត្វល្អិតមួយប្រភេទស្រដៀងនឹងកំពោង កញ្ចែ។

## គ

គិរី (ន.) : ភ្នំ។

គែន (ន.) : ឧបករណ៍ភ្លេងសម្រាប់ផ្លុំរបស់ជនជាតិដើមភាគតិច។

## ឃ

ឃោរឃៅ (គុ.) : ខ្លាំងក្រៃ ពន្លឹកគួរឱ្យខ្លាច។

ឃ្មើស (គុ.) : ដែលទើស ទាក់ ទាស់។

## ង

ងឿ (ន.) : ក្តារក្រាស់បន្ទះធំៗពីរ ឬបីសន្លឹកតម្រៀបភ្ជិតគ្នាលើជើងម៉ាទ្រក្តារងឿ។

## ច

ចារ (កិ.) : ធ្វើរបងទាបដោយដោតចម្រឹងឱ្យជាចារីក ចារចំណារ។

(កិ.) : សរសេរដោយដែកចារ : ចារសាស្ត្រា។

(ន.) : ឈ្មោះឈើម្យ៉ាងមានផ្កាសម្បុរក្រហម ក្លិនឆ្អាប ដើមចារ ផ្កាចារ។

ច្បាប់ (ន.) : សេចក្តីបញ្ញត្តិ វិន័យ ក្រឹត្យក្រម ក្បួនប្រដៅមនុស្សឱ្យប្រព្រឹត្តល្អ។

ច្បាប់ក្រម (ន.) : ឈ្មោះសាស្ត្រាសុភាសិតសម្រាយកាព្យ។

ច្យុត (កិ.) : ឃ្លាត របូត ស្លាប់(ច្រើននិយាយជាមួយទេវតាអស់ជីវិត)។

## ឆ

ឆ្មាបា (ន.) : សត្វព្រៃមានស្បែកជាស្លាបមួយប្រភេទ សម្រែកស្រដៀងនឹងឆ្មា ។

## ជ

ជម (កិ.) : ធ្វើឱ្យមានរាងជ្រលម ព្រួមឱ្យមានរាងដូចត្រយូងចេក ។
*ឧទាហរណ៍ :* យកស្លឹកត្នោតមកជមជាកន្ទោង ។

ជ្ជូត (កិ.) : រុំក្បាលដោយឈ្នួត ។

ជំនាញ (គុ.) : ដែលចេះស្ទាត់ប្រាកដ ។

ជ្វាលា (ន.) : អណ្តាតភ្លើង សេចក្តីរុងរឿង ពន្លឺដែលភ្លឺព្រោងព្រាត ។

## ឈ

ឈ្មុស (ន.) : សត្វជើងបួន ពពួកសំពោចមានក្លិនទឹកកាមប្រហើរកាយសម្រាប់ឱ្យផ្សំធ្វើទឹកអប់ ។

(កិ.) : ឈ្មុសគាស់ដីដោយចុងច្រមុះ : ជ្រូកឈ្មុសដី ។

## ញ

ញោះ (កិ.) : សំពងដោយពាក្យសម្តី : ខ្ញុំញោះមួយម៉ាត់ទៅគាត់ច្រឡោតតូង ។

## ដ

ដំបៅងា (ន.) : ប្រភេទដំបៅម្យ៉ាងមិនងាយជា ។

## ឋ

ឋានីយ (ន.) : ទីសម្រាប់សំចត កន្លែងចតយាន ឋានីយរទេះភ្លើង ។

## ឌ

ឌី (កិ.) : ផ្តើនឱ្យ និយាយផ្តើន : ស្តីប្រដៅទៅវាឌីមកវិញ ។
បើ (កិ.វិ.) និយាយឌី , ជេរឌី ។

## ឍ

ឍាមរា (ន.) : ក្ងាន ហង្ស ។

## ណ

ចំណេះ (ន.) : សេចក្តីចេះ , ដំណើរដែលចេះ ។

## ត

ត្បាល់ក្តឿង (ន.) : ត្បាល់ដែលមានអង្រែជាប់នឹងដងសម្រាប់ជាន់ បុកស្រូវជាដើម ។

ត្មាតភ្លើង (ន.) : ឈ្មោះសត្វស្លាបមួយប្រភេទមានមាឌធំក្បាលក្រហមដូចភ្លើង ។

## ថ

ថេរ (គុ.) : មាំមួន , ខ្ជាប់ខ្ជួន , យឺនយូរ , សម្រាប់និយាយផ្សំនឹងពាក្យឋិត : ឋិតថេរ គឺតាំងនៅមាំ , យឺនយូរ ។

## ទ

ទ្រមែ (គុ.) : តូចទាបរាងសាយក្រោម ទាបទ្រមែ ។

## ធ

ធូរ (គុ.) : ទីទៃពីតឹង គឺងាយ , ទូលាយ

(កិ.) : ស្រាក , ស្បើយ (ជំងឺ) : ជំងឺជីតាខ្ញុំថ្ងៃនេះបានស្បើយបន្តិច ។

## ន

គំនូរ (ន.) : រូបភាព , ក្បាច់រចនា , ក្បូរក្បាច់រំលេច ... ដែលកើតមានឡើងដោយការគូរ : គំនូររឿងទន្សាយចង់ស៊ីចេក ។

## ប

បូជា (កិ.) : ថ្វាយ ជូន ។

(កិ.) : ដុត រំលាយ(សព) ។

ប៉ែន (ន.) : ប្រដាប់ធ្វើដោយដែក មានរន្ធតូចសម្រាប់ហូត ឬរោយ(នំបញ្ចុក) ។

## ផ

ផាល (ន.) : ដែករាងជម មុខមុតសម្រាប់ដាក់ប្រហាកត្រង់ពន្លួញចុងផ្ទៀងនង្គ័ល ។

(ន.) : អវយវៈដែលក្លាយជារោគមានសណ្ឋានស្រដៀងនឹងផាលនៅត្រង់ចុងឆ្អឹងជំនីររបស់មនុស្ស(ចុងត្រង់ផាល) ។

## ព

ពាល (គុ.) : ល្ងង់ខ្លៅ កាចសាហាវអាក្រក់ ។

ព្យាម (ន.) : ប្រវែងមួយកាងដៃ ស្មើនឹងបួនហត្ថ ។

ព្លែម (កិ.វិ.) : អំពីអាការបញ្ចេញអណ្ដាតលិទ្ធបបូរមាត់រឿយៗ ។

## ភ

ភាស៊ី (ន.) : ពន្ធទំនិញ គឺពន្ធដែលអ្នករាជការដកហូតពីអ្នកលក់ទំនិញ ។

ភ្វារ (កិ.) : ភ្ញាក់មួយភាំងពីដេកលក់ ។

ភ្វីទៀន (ន.) : ឈ្មោះគ្រឿងអុចជាលម្អ មានដងដាំបញ្ឈរធ្វើពីឫស្សី ។

## ម

មាយា (ន.) : កល កិច្ចកល ល្បិចល្បង ពុតត្បុត ។

ម្រុំ ឬម្រុម (ន.) : ឈ្មោះឈើមួយប្រភេទមែកស្រួយឆាប់បាក់ ស្លឹកខ្ចីប្រើជាបន្លែ ។

## យ

យាគូ (ន.) : បបរ ។

យីកេ (ន.) : ឈ្មោះល្បែងមហោស្រពមួយប្រភេទ លេងស្រដៀងនឹងល្ខោន ។

យីហ៊ុប (ន.) : ឈ្មោះឈើផ្កាមួយប្រភេទ ។

## រ

រយ៉ា (ន.) : គ្រឿងព្យួរមានរំយោល សម្រាប់ពាក់នឹងត្រចៀក ។

រលីបរលាប (គុ. ឬកិ.វិ.) : ដែលនៅសល់បន្តិចបន្តួចរលាបៗ ។

## ល

លំចង់ (ន.) : ឈ្មោះវាវីជាតិមួយប្រភេទ ដើមសម្បុរស្វាយស្រគាំ ផ្កាសម្បុរខៀវស្វាយ ។

ល្ខោនខោល (ន.) : ឈ្មោះល្បែងមហោស្រពមួយប្រភេទដែលអ្នកសម្តែង មានពាក់ក្បាំងមុខ ។

## វ

វិស័យ (ន.) : ទី តំបន់ បរិវេណ ផ្នែក : វិស័យអប់រំ វិស័យសេដ្ឋកិច្ច ។

## ស

សាគរ (ន.) : សមុទ្រ ។

សាធុ (គុ.) : ល្អប្រពៃ ត្រឹមត្រូវ ដែលឱ្យសម្រេចប្រយោជន៍ ។

សេកសោម (ន.) : សេកមានមាឌធំនិងមានចំពុះក្រហម ។

សម្ព័ន្ធ (ន.) : ការចងភ្ជាប់ ការតភ្ជាប់គ្នា ដំណើរទាក់ទងរកគ្នា ។

សម្ភព (ន.) : ការកើតព្រម ការកើតដោយល្អ ។

ស្វិតថៅ (ន.) : ឈ្មោះបក្សីមួយប្រភេទ មាឌតូច ពួកចាបយំឮសូរសព្ទស្រមៃ ហាក់ដូចជាពាក្យថា ស្វិតថៅៗ! ...ឬថា ស្វិតទេថៅៗ ។

ស្វិតស្វាញ (គុ.) : កំណាញ់ស្វិតស្អិតល្អិតមិនងាយនឹងចាយទ្រព្យ កំណាញ់ក្រៅតម្រា : កំណាញ់ស្វិតស្វាញ ។

(គុ.) : ដែលសាញទទូចមិនងាយព្រម មិនងាយលែង : សម្តីស្វិតស្វាញ មនុស្សស្វិតស្វាញ ។

## ហ

ហើរ (កិ.) : ទៅឯអាកាសដោយកម្លាំងស្លាបជក់ខ្យល់ : ចាបហើរ ។ ខ្ចរខ្ចាយទៅ : សម្តីហើរតាមខ្យល់ ។

(គុ.) : ដែលថយខ្សោយពណ៌ : សំពត់ហើរពណ៌ ។

## ឡ

ឡេះឡោះ (គុ. ឬកិ.វិ.) : ដែលលាយដោយការលេង ឥតយកជាការពិតពុំបាន សម្តីឡេះឡោះនិយាយឡេះឡោះ ។

## អ

អំបោះ (ន.) : សរសៃសំឡីដែលរវៃរួចហើយមានប្រវែងវែងៗ សម្រាប់ត្បាញសំពត់ : អំបោះនៅ សំពត់អំបោះ ។

## ស្រះពេញតួ

ឮដ៏ (និ.) : ត្រង់ នា នៅនា ឯ ។

# តារាងព្យញ្ជនៈ




បោះពុម្ពដោយ គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

13 145
iBC INTERNATIONAL BOOK CENTER
$ 3.00